00600707

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

-8-

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification):
10 / 09 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

***តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ***

**សំណុំរឿងព្រហ្មទណ្ឌលេខ:** ០០២/១៧-០៦-២០១០-អវតក-អបជ(០៨)

**ចំពោះមុខ:**
**ចៅក្រម ប្រាក់ គឹមសាន, ប្រធាន**
**ចៅក្រម Rowan DOWNING**
**ចៅក្រម ន័យ ថុល**
**ចៅក្រម Catherine MACHI-UHEL**
**ចៅក្រម ហួត វុទ្ធី**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception):
10 / 09 / 2010
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**កាលបរិច្ឆេទ:** ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០

---

**សាធារណៈ(ដោយកោសលុប)**

**សាលដីកាលើបណ្តឹងជំទាស់ ចៅក្រម យូ ប៊ុនឡេង**

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY
យ៉េត ចរិយា
William SMITH

**ជនត្រូវចោទ**
នួន ជា

**សហចៅក្រមស៊ើបអង្កេត**
ចៅក្រម យូ ប៊ុនឡេង

**សហមេធាវីការពារក្តីជនត្រូវចោទ**
សុន អរុណ
Michiel PESTMAN
Vitor KOPPE

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C * C.E.T.C

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (“**អ.វ.ត.ក**”) បានទទួលបណ្ដឹងមិតចិត្តចៅក្រម យូ ប៊ុនឡេង” “បណ្ដឹងមិតចិត្ត” ដែលធ្វើឡើងដោយសហមេធាវីរបស់លោក នួន ជា (“ជនត្រូវចោទ” និង “ម្ចាស់បណ្ដឹងមិតចិត្ត”) នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១០ និងត្រូវបានជូនដំណឹងនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០[១]។

## I. ប្រវត្តិនីតិវិធី

១. ក្នុងបណ្ដឹងរបស់ខ្លួន ម្ចាស់បណ្ដឹងមិតចិត្តបានស្នើសុំ “កុំឱ្យចៅក្រម យូ ប៊ុនឡេង ចូលរួមក្នុងនីតិវិធីណាមួយ និងដំណើរការនីតិវិធីទាំងឡាយនៃសំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/កសចស (“សំណុំរឿង ០០២”)[២]។

២. នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០ សហមេធាវីការពារជនត្រូវចោទ អៀង ធីរិទ្ធ បានដាក់ “ការអនុម័តយកបណ្ដឹងមិតចិត្តរបស់មេធាវីការពាររបស់លោក នួន ជា នៃបណ្ដឹងមិតចិត្តចៅក្រម យូ ប៊ុនឡេង ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១០” (“ការអនុម័តយករបស់ អៀង ធីរិទ្ធ”)[៣] ដោយជូនដំណឹងអង្គបុរេជំនុំជម្រះថា អៀង ធីរិទ្ធ “អនុម័តយកអំណះអំណាងទាំងឡាយដែលបានលើកឡើង និងដំណោះស្រាយដែលបានទាមទារនៅក្នុងបណ្ដឹងមិតចិត្ត”[៤]។

៣. សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង (ចៅក្រម យូ ប៊ុនឡេង) បានដាក់ “ចម្លើយតបរបស់ខ្លួនឆ្លើយតបទៅនឹងបណ្ដឹងមិតចិត្ត ដែលធ្វើឡើងដោយមេធាវីការពាររបស់លោក នួន ជា នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០ និងត្រូវបានជូនដំណឹងនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១០[៥]។

៤. នៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១០ ផ្នែកគ្រប់គ្រងតុលាការនៃ អវតក បានជូនដំណឹងអំពី “សេចក្ដីព្រមានចំពោះការផ្សព្វផ្សាយព័ត៌មានសម្ងាត់ដោយគ្មានការអនុញ្ញាត”[៦] របស់អង្គបុរេជំនុំជម្រះ។

---

[១] ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១០ ឯកសារលេខ១, ERN00535168-00535181។

[២] បណ្ដឹងមិតចិត្តចៅក្រម យូ ប៊ុនឡេង, កថាខណ្ឌ១ *សូមអាន* កថាខណ្ឌ២៧ *ផងដែរ*។

[៣] ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០, ឯកសារលេខ២, ERN00539199-00539200។

[៤] មេធាវី អៀង ធីរិទ្ធ អនុម័តយកបណ្ដឹងមិតចិត្ត, កថាខណ្ឌ២។

[៥] ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១០, ឯកសារលេខ៣, ERN00543507-00543519។

PRE-TRIAL CHAMBER • E.C.C.C • C.E.T.C • CHAMBRE PRÉLIMINAIRE

៥. សហមេធាវីរបស់ម្ចាស់បណ្តឹងជំទាស់ បានដាក់ "សេចក្តីបន្ថែមលើបណ្តឹងជំទាស់ចៅក្រម យូ ប៊ុនឡេង" ("សេចក្តីបន្ថែម")[៧] នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ ហើយត្រូវបានជូនដំណឹងនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១០។

៦. នៅថ្ងៃទី២ ខែសីហា ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានចេញ "សេចក្តីសម្រេចលើសេចក្តីបន្ថែមលើបណ្តឹងជំទាស់ចៅក្រម យូ ប៊ុនឡេង" ("សេចក្តីសម្រេចលើសេចក្តីបន្ថែម") ដែលក្នុងសេចក្តីសម្រេចនោះ អង្គបុរេជំនុំជម្រះបានសម្រេចថា៖

> [៥] ផ្នែកទីមួយនៃសំណើបន្ថែមគឺជាសារណារបស់ម្ចាស់បណ្តឹងជំទាស់ ស្តីពីរបាយការណ៍ថ្មីៗ ចុះផ្សាយដោយអង្គការ Open Society Justice Initiative នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១០ ដែលមានចំណងជើងថា "ការជ្រៀតជ្រែកខាងនយោបាយនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា" ("របាយការណ៍ OSJI")[៨]។ ម្ចាស់បណ្តឹងជំទាស់ផ្អែកលើរបាយការណ៍របស់ OSJI សម្រាប់សារណារបស់ខ្លួន ដោយបញ្ជាក់ថារបាយការណ៍នោះជា "ភស្តុតាងបញ្ជាក់"[៩] "បណ្តឹងជំទាស់សហចៅក្រម យូ ប៊ុនឡេង កុំឱ្យចៅក្រមរូបនេះចូលរួមរាល់ដំណើរការនីតិវិធីទាំងឡាយក្នុងសំណុំរឿង ០០២"[១០]។
>
> [៦] អង្គបុរេជំនុំជម្រះរក្សាទុកសេចក្តីសម្រេចរបស់ខ្លួនអំពីភាពអាចទទួលយកបាន និងអង្គសេចក្តីនៃផ្នែកទីមួយនៃសេចក្តីបន្ថែម សម្រាប់ការចេញសាលដីកាដែលមានសម្អាងហេតុពេញលេញរបស់ខ្លួនទៅលើបណ្តឹងជំទាស់ ដែលនឹងត្រូវចេញក្នុងពេលវេលាមួយសមស្របខាងមុខ។
>
> [៩] អង្គបុរេជំនុំជម្រះយល់ឃើញថា ផ្នែកទីពីរនៃសេចក្តីបន្ថែម ទាក់ទងទៅនឹងលោក Knut Rosandhaug មិនអាចទទួលយកបាននោះទេ ដោយសារវាមិនមានគុណវុឌ្ឍិជា "ភស្តុតាងគាំទ្រ" ស្របទៅនឹងអត្ថន័យនៅក្នុងវិធាន ៣៤(៣) នៃវិធានផ្ទៃក្នុងនោះទេ។

---

[៦] ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១០, ឯកសារលេខ៤, (ERN00543130-00543134) និងឯកសារ D314/1/11, រួមបញ្ចូលទាំងសំណើសុំកែតម្រូវ ឯកសារ D314/1/11 Corr-1។ ផ្នែកនៃសេចក្តីព្រមានជាសាធារណៈក៏ត្រូវបានជូនដំណឹងផងដែរនៅថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១០។

[៧] ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០, ឯកសារលេខ៥ ERN00568724-00568728។

[៨] http://www.soros.org/initiatives/justice (ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០)។ *សូមមើល* សេចក្តីបន្ថែមលើបណ្តឹងជំទាស់, កថាខណ្ឌ១-៥,៧-៨, ១០។

[៩] វិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង។

[១០] សេចក្តីបន្ថែមលើបណ្តឹងជំទាស់, កថាខណ្ឌ១០។

[១០] ទោះជាយ៉ាងណាក៏ដោយ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ការព្រួយបារម្ភរបស់ដើមបណ្តឹងឧទ្ធរណ៍ថា "វាទំនងណាស់ថា សាធារណជននឹងបកស្រាយមិនត្រឹមត្រូវអំពីជំហរ*ផ្ទាល់ខ្លួន*របស់លោក Rosandhaugថា ដូចនឹងជំហររបស់អង្គបុរេជំនុំជម្រះដែរ" នឹងត្រូវបានដោះស្រាយគ្រប់គ្រាន់ តាមរយៈការជូនដំណឹងតាមអត្ថបទសម្រាប់សាធារណជនដែលត្រូវបានកែសម្រួលពីសាលដីកាដែលមានសំអាងហេតុពេញលេញរបស់អង្គបុរេជំនុំជម្រះទៅលើបណ្តឹងជំទាស់នេះដែលនឹងត្រូវចេញនៅក្នុងពេលវេលាមួយសមស្របខាងមុខ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ:**

១. **ណែនាំឲ្យ** ចៅក្រម យូ ប៊ុនឡេង ដាក់សារណាលាយលក្ខណ៍អក្សរបន្ថែមជូនអង្គបុរេជំនុំជម្រះដើម្បីឆ្លើយតបទៅនឹងអំណះអំណាងរបស់ម្ចាស់បណ្តឹងជំទាស់ក្នុងសេចក្តីបន្ថែមស្តីពីរបាយការណ៍ OSJI ក្នុងរយៈពេលដប់ (១០)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងពីសេចក្តីបន្ថែម ពោលគឺនៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០១០ ប្រសិនបើលោកចៅក្រមមានបំណងចង់ដាក់សារណានេះ។

២. **បដិសេធចោល** ទឡ្ហីករណ៍ក្នុងសេចក្តីបន្ថែមដែលពាក់ព័ន្ធនឹងលោក Knut Rosandhaug[១១]។

៧. នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០១០ ចៅក្រមយូ ប៊ុនឡេង បានដាក់ "សេចក្តីសង្កេតបន្ថែមលើសេចក្តីបន្ថែមនៃបណ្តឹងជំទាស់របស់លោក នួន ជា"[១២] ("សេចក្តីសង្កេតលើសេចក្តីបន្ថែម")។ ចៅក្រមយូ ប៊ុនឡេង បានបញ្ជាក់នៅក្នុងសេចក្តីសង្កេតលើសេចក្តីបន្ថែមថា "ខ្ញុំគ្មានចេតនាបន្ថែមសេចក្តីសង្កេតលើសេចក្តីបន្ថែមនៃបណ្តឹងជំទាស់របស់លោក នួន ជា ក្រៅពីអ្វីដែលខ្ញុំបានបញ្ជាក់ក្នុងសេចក្តីសង្កេតពីមុនរបស់ខ្ញុំឡើយ និងជាពិសេសសេចក្តីសង្កេតនៅក្នុងសេចក្តីប្រកាសព័ត៌មានរួមជាសាធារណៈដែលសហចៅក្រមស៊ើបអង្កេតទាំងពីររូបបានធ្វើឡើង ពាក់ព័ន្ធនឹងសំណុំរឿងលេខ ០០៣ និង ០០៤"។

## II. បញ្ហាបឋម

**ក. សំណើសុំឲ្យបើកកិច្ចស៊ើបសួរ និង/ឬ សវនាការផ្ទាល់មាត់**

[១១] ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១០, ឯកសារលេខ៦, ERN00577612-00577615។

[១២] ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១០, ឯកសារលេខ៧, ERN00578909-00578909។

**សារណារបស់ភាគី**

៨. ម្ចាស់បណ្តឹងឧទ្ធរណ៍បាន "បញ្ជាក់ថា ខ្លួនបានផ្តល់ភស្តុតាងគ្រប់គ្រាន់សម្រាប់គាំទ្រ [បណ្តឹងនេះ]"[១៣]។ ទោះជាយ៉ាងណាក៏ដោយ ម្ចាស់បណ្តឹងឧទ្ធរណ៍បានបញ្ជាក់ដូចខាងក្រោមនេះ៖

> ប្រសិនបើអង្គបុរេជំនុំជម្រះ យល់ឃើញថាភស្តុតាងបន្ថែមទៀតអាចមានប្រយោជន៍ដល់ការធ្វើសេចក្តីសម្រេចរបស់ខ្លួន អនុលោមតាមអំណាចឆន្ទានុសិទ្ធិរបស់ខ្លួន អង្គបុរេជំនុំជម្រះ*អាច* (១) បង្គាប់ឱ្យបើកកិច្ចស៊ើបសួរទៅក្នុងកាលៈទេសៈជុំវិញអំពើអកម្មរបស់ចៅក្រម យូ ប៊ុនឡេង និង/ឬ (២) បើកសវនាការដេញដោលជាសាធារណៈទៅលើបញ្ហា ដោយមានការចូលរួមពេញលេញពីភាគីទាំងអស់...[១៤]

៩. ដូចដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានកត់សម្គាល់[១៥] អង្គបុរេជំនុំជម្រះបានសម្រេចពីមុនថា ខ្លួនគ្មានសមត្ថកិច្ចក្នុងការ "បង្គាប់ឱ្យបើកកិច្ចស៊ើបអង្កេតទៅលើការចោទប្រកាន់ពីភាពលម្អៀង ដែលខ្វះភស្តុតាងគ្រប់គ្រាន់ទេ"[១៦] នោះទេ។ ម្ចាស់បណ្តឹងឧទ្ធរណ៍បានបញ្ជាក់ថា "គោលជំហរដ៏សាមញ្ញនេះ [របស់អង្គបុរេជំនុំជម្រះ] គឺថា នៅពេលដែល "ភស្តុតាងគ្រប់គ្រាន់" ត្រូវបានបង្ហាញ នោះអង្គបុរេជំនុំជម្រះអាចចាត់វិធានការ តាមអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនបាន"[១៧]។

១០. ក្នុងចម្លើយតបរបស់ខ្លួន សហចៅក្រមបានស្នើឱ្យអង្គបុរេជំនុំជម្រះ ច្រានចោលសំណើសុំបើកសវនាការសាធារណៈរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ពីព្រោះ "នីតិវិធីនៃបណ្តឹងឧទ្ធរណ៍ដែលមានចែងក្នុងវិធាន ៣៤ គឺជានីតិវិធីសម្ងាត់ ហើយរាល់ការរៀបចំសវនាការសាធារណៈ និងការចូលរួមរបស់សហចៅក្រមស៊ើបអង្កេតទាំង២ នឹងប៉ះពាល់យ៉ាងខ្លាំងដល់សំណុំរឿងស៊ើបសួរ ០០២ ដែល

---

[១៣] បណ្តឹងឧទ្ធរណ៍ចៅក្រម យូ ប៊ុនឡេង, កថាខណ្ឌ២៥។

[១៤] បណ្តឹងឧទ្ធរណ៍ចៅក្រម យូ ប៊ុនឡេង, កថាខណ្ឌ២៦ (ជើងទំព័រត្រូវបានលុបចោល; គូសបញ្ជាក់បន្ថែមក្នុងច្បាប់ដើម)។

[១៥] បណ្តឹងឧទ្ធរណ៍ចៅក្រម យូ ប៊ុនឡេង, កថាខណ្ឌ១៨។

[១៦] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ចំពោះចៅក្រម Marcel Lemonde, ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០, ០០២/២៩-១០-២០០៩-អ.វ.ត.ក/អ.ជ.ប(០៥), ឯកសារលេខ៥, ERN 00485317-00485329, កថាខណ្ឌ២០ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ចំពោះចៅក្រម Marcel Lemonde")។

[១៧] បណ្តឹងឧទ្ធរណ៍ចៅក្រម យូ ប៊ុនឡេង, កថាខណ្ឌ១៨។

កំពុងតែបញ្ចប់ ជាពិសេសនៅដំណាក់កាលដែលយើងខ្ញុំ កំពុងតែមមាញឹកក្នុងការតាក់តែងដីកាដំណោះស្រាយនេះ”[១៨]។

**ការពិចារណារបស់អង្គបុរេជំនុំជម្រះ**

១១. បណ្តឹងដិតចិត្តបានបញ្ជាក់ច្បាស់ថា ម្ចាស់បណ្តឹងដិតចិត្តស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរ និងបើកសវនាការសាធារណៈ ក្នុងករណីដែលអង្គបុរេជំនុំជម្រះរកឃើញថា “ភស្តុតាងបន្ថែមទៀតអាចមានប្រយោជន៍ដល់ការធ្វើសេចក្តីសម្រេចរបស់ខ្លួន”។ ដោយសារអង្គបុរេជំនុំជម្រះសម្រេចថាមិនស្វែងរកភស្តុតាងបែបនេះទេ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះមិនមានភារកិច្ចត្រូវយកសំណើនេះមកពិចារណាតទៅទៀតឡើយ។

## III. ភាពអាចទទួលយកបាននៃបណ្តឹងដិតចិត្ត

**ក. រយៈពេលកំណត់នៃការដាក់បណ្តឹង**

**សារណារបស់ភាគី**

១២. អង្គបុរេជំនុំជម្រះសូមរំលឹកថា ភាគីត្រូវតែដាក់បណ្តឹងដិតចិត្ត “ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីបានដឹងអំពីមូលហេតុនោះ”[១៩] ហើយ “ភាគីត្រូវតែដាក់បណ្តឹងនេះ ... ឱ្យបានមុនពេលចេញដីកាដំណោះស្រាយ”[២០]។ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថាបណ្តឹងដិតចិត្តនិងសេចក្តីបន្ថែម បានបំពេញតាមលក្ខខណ្ឌទីពីរ នៃលក្ខខណ្ឌដែលត្រូវមានទាំងពីរ។

១៣. ចំពោះលក្ខខណ្ឌទីមួយ ម្ចាស់បណ្តឹងដិតចិត្តបញ្ជាក់ថា “វិធាន៣៤(៣) ចែងតម្រូវថា ពាក្យបណ្តឹងត្រូវបានដាក់ភ្លាម បន្ទាប់ពីមេធាវីការពារក្តីបានដឹងអំពីទង្វើរបស់ចៅក្រម យូ ប៊ុនឡេង”[២១]។ ក្នុងខ្លឹមសារលេខយោង ម្ចាស់បណ្តឹងដិតចិត្តបានបញ្ជាក់ថា “វិធាន៣៤(៣) ចែងតម្រូវថា ពាក្យ

---

[១៨] ចម្លើយតប, កថាខណ្ឌ៣៣។

[១៩] វិធាន៣៤(៣) នៃវិធានផ្ទៃក្នុង។

[២០] វិធាន៣៤(៤)(ក) នៃវិធានផ្ទៃក្នុង។

[២១] បណ្តឹងដិតចិត្តចៅក្រម យូ ប៊ុនឡេង, កថាខណ្ឌ១៩។

បណ្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីដាក់ពាក្យបណ្តឹងបានដឹងអំពីមូលហេតុ"នោះ គេក៏ត្រូវតែយកមកពិចារណាផងដែរ នូវពេលវេលាបន្ថែមដែលត្រូវការសម្រាប់បកប្រែសេចក្តីសន្និដ្ឋាន និងឯកសារគាំទ្រនានា"[២២]។

១៤. ចៅក្រម យូ ប៊ុនឡេង បានអះអាងថាបណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានទេ ពីព្រោះពាក្យបណ្តឹងមិនត្រូវបានធ្វើឡើងឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីបានដឹងអំពីមូលហេតុនោះ។ ចម្លើយតបរបស់គាត់បានបញ្ជាក់ដូចខាងក្រោមនេះ៖

> នៅក្នុងពាក្យបណ្តឹងឧទ្ធរណ៍ អង្គហេតុជាចំបងដែលលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍គឺត្រូវបានលើកឡើងជាយូរណាស់មកហើយ ហើយមេធាវីការពារក្តីក៏ធ្លាប់យកអង្គហេតុទាំងនេះទៅប្រើប្រាស់រួចហើយនៅក្នុងបណ្តឹងមុនៗ។ មានតែអង្គហេតុទាក់ទងនឹងចំណាត់ការរបស់ខ្ញុំលើសំណុំរឿង ០០៣ និង ០០៤ ប៉ុណ្ណោះដែលជាអង្គហេតុថ្មី ប៉ុន្តែវាជាចំណាត់ការនៅក្នុងក្របខណ្ឌនៃសំណុំរឿងផ្សេង ដែលមិនមានការពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២ ដែលមេធាវីកំពុងការពារក្តីឡើយ។ ហេតុដូច្នេះ ក្រុមមេធាវីការពារក្តីខកខានមិនបានប្តឹង ហើយគ្មានឧបសគ្គអ្វីដែលរារាំងឡើយ ប្រសិនបើក្រុមមេធាវីចង់ប្តឹងអំពីអង្គហេតុទាំងនោះ។ អនុលោមតាមខ្លឹមសារនៃបញ្ញត្តិច្បាប់ខាងលើ បើទោះបីជាមូលហេតុ និងភស្តុតាងដែលលើកឡើងដោយក្រុមមេធាវីការពារក្តីពិតក្តី ប្រសិនបើក្រុមមេធាវីខកខានមិនបានប្តឹង ការប្តឹងនាពេលក្រោយបែបនេះមិនអាចទទួលយកបានឡើយ។
>
> ...
>
> ផ្លៀតឱកាសនេះខ្ញុំសូម ... ស្នើសុំឱ្យអង្គបុរេជំនុំជម្រះសម្រេចមិនទទួលយកបណ្តឹងដោយហេតុថា ការដាក់បណ្តឹងឧទ្ធរណ៍នេះធ្វើឡើង ... ក្នុងពេលវេលាមិនសមស្រប[២៣]។

**ការពិចារណារបស់អង្គបុរេជំនុំជម្រះ**

១៥. ជាបឋម អង្គបុរេជំនុំជម្រះត្រូវតែកំណត់ "មូលដ្ឋាននៃបណ្តឹង" តាមអត្ថន័យនៃវិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះយល់ឃើញថា ពាក្យថា "មូលហេតុនៃការប្តឹងឧទ្ធរណ៍" ក្នុងមាត្រា

---

[២២] បណ្តឹងឧទ្ធរណ៍ចៅក្រម យូ ប៊ុនឡេង, ជើងទំព័រលេខ៥៧។

[២៣] ចម្លើយតប, កថាខណ្ឌ១១-១២ (ជើងទំព័រត្រូវបានលុប, គូសបញ្ជាក់ក្នុងច្បាប់ដើម)។

00600714



៥៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា[២៤] និងពាក្យថា "មូលហេតុនៃបណ្ដឹង" ក្នុងវិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង មិនមានភាពខុសគ្នាខាងផ្លូវច្បាប់ទេ។

១៦. ពាក្យបណ្ដឹងមិនបានបញ្ជាក់ឱ្យបានច្បាស់លាស់ពីមូលហេតុនៃបណ្ដឹងជំទាស់បែបនេះឡើយ។ "សេចក្ដីផ្ដើម" នៃបណ្ដឹងជំទាស់នោះបានបញ្ជាក់ថា៖

> យោងទៅលើ: (i) ប្រវត្តិនៃការជ្រៀតជ្រែកពីសំណាក់អង្គការនីតិប្រតិបត្តិមកលើតុលាការកម្ពុជា ដែលត្រូវបានចងក្រងជាឯកសារយ៉ាងល្អ (ii) ជំហរយ៉ាងរឹងប៉ឹង និងជាហូរហែរបស់មន្ត្រីនានាក្នុងរដ្ឋាភិបាល ទៅលើបញ្ហាតុលាការសុទ្ធសាធនៅអង្គជំនុំជម្រះវិសាមញ្ញ និង (iii) ការប្រព្រឹត្តិរបស់ចៅក្រម យូ ប៊ុនឡេង ទៅលើសំណើរបស់ក្រុមមេធាវីការពារក្តីស្នើឱ្យកោះហៅសាក្សីមានមុខតំណែងខ្ពស់ក្នុងរដ្ឋាភិបាល និងសេចក្ដីសម្រេចថ្មីៗរបស់គាត់ "មិនចុះហត្ថលេខា"លើដីកាចាត់ឱ្យស៊ើបសួរជំនួសជាក់លាក់មួយចំនួនដែល នៅក្នុង ... ("សំណុំរឿង០០៣ និង០០៤") អាចនាំឱ្យអ្នកអង្កេតការឯករាជ្យសន្និដ្ឋានថា គាត់ខ្វះឯករាជ្យភាពដែលតម្រូវដោយការិយាល័យរបស់គាត់។ អាស្រ័យហេតុនេះ ការបន្តការពាក់ព័ន្ធរបស់គាត់នៅក្នុងសំណុំរឿង ០០២ នឹងបង្កើតជាការរំលោភសិទ្ធិរបស់ នួន ជា ដែលត្រូវស៊ើបអង្កេតដោយតុលាការមួយដែលឯករាជ្យ និងថែមទាំងធ្វើឱ្យប៉ះពាល់ដល់ទំនុកចិត្ត និងសុច្ចរិតភាពរបស់ អវតក[២៥] ទៀតផង។

១៧. បណ្ដឹងជំទាស់បានបញ្ជាក់ នៅក្នុងផ្នែកដែលនិយាយពី "អំណះអំណាង" ត្រង់អនុផ្នែកដែលមានចំណងជើងថា "ការវាយតម្លៃជាសត្យានុមតិត្រូវបានបំពេញ" ថា៖

> មូលហេតុនៃបណ្ដឹងជំទាស់នេះ គឺងាយយល់ទេ៖ ទង្វើរបស់ចៅក្រម យូ ប៊ុនឡេង ទៅលើដំណើការនៃកិច្ចស៊ើបសួរ នឹងធ្វើឱ្យអ្នកអង្កេតការឥតលម្អៀងនិងមានព័ត៌មានគ្រប់គ្រាន់ សន្និដ្ឋានដោយសមហេតុផលថា ចៅក្រម យូ ប៊ុនឡេង ខ្វះភាពឯករាជ្យ។

---

[២៤] "ភាគីត្រូវតែដាក់បណ្ដឹងជំទាស់ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលណាដែលខ្លួនបានដឹងពីមូលហេតុនេះ។ ការខកខានមិនបានដាក់បណ្ដឹងទាន់ពេលវេលានឹងនាំឱ្យបណ្ដឹងមិនអាចទទួលយកបាន"។ មាត្រា ៥៥៨ ក៏បានចែងផងដែរថា "បណ្ដឹងត្រូវតែចង្អុលឱ្យបានច្បាស់លាស់អំពីមូលហេតុនៃការប្ដឹងជំទាស់ ហើយត្រូវមានភស្តុតាងបញ្ជាក់ច្បាស់លាស់ បើពុំដូច្នោះទេ ពាក្យប្ដឹងមិនអាចទទួលយកបានឡើយ"។

[២៥] បណ្ដឹងជំទាស់ចៅក្រម យូ ប៊ុនឡេង, កថាខណ្ឌ១។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

យ៉ាងហោចណាស់ក៏ពេលបីដងដែរ ដែល ចៅក្រម យូ ប៊ុនឡេង បានបង្ហាញពីឆន្ទៈយ៉ាងច្បាស់ក្រឡែតដែលបានប្រើប្រាស់អំណាចតុលាការរបស់គាត់ដោយមិនត្រឹមត្រូវ ក្នុងការបំពេញការងារឱ្យរបៀបវារៈរបស់រដ្ឋាភិបាល៖

ក. ការជំទាស់របស់គាត់មិនព្រមចុះហត្ថលេខាលើលិខិតរបស់ កសចស ផ្ញើទៅ[redacted] ដើម្បីសុំសម្ភាស[redacted] គឺស្របគ្នានឹងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីទប់ស្កាត់ការបញ្ជូនលិខិតនោះទៅ[redacted]។

ខ. ការជំទាស់របស់គាត់មិនព្រមចុះហត្ថលេខាលើដីការបស់ កសចស ដើម្បីកោះអញ្ជើញមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់កម្ពុជាប្រាំមួយរូប គឺស្របគ្នាទៅនឹងការថ្លែងរបស់នាយករដ្ឋមន្ត្រីកម្ពុជា (ដែលថារូបលោកផ្ទាល់បានទប់ស្កាត់មិនឱ្យមានការផ្តល់សក្ខីកម្មពីបុគ្គលមួយចំនួន) និងការថ្លែងពីសំណាក់រដ្ឋមន្ត្រីក្រសួងព័ត៌មានកម្ពុជា (ដែលថាយោងទៅតាមរាជរដ្ឋាភិបាលកម្ពុជា បុគ្គលប្រាំមួយរូបដែលត្រូវកោះហៅនោះ មិនគួរផ្តល់សក្ខីកម្មឡើយ)។

គ. ហើយនៅពេលថ្មីៗនេះ គាត់ "មិនព្រមចុះហត្ថលេខា" លើដីកាចាត់ឱ្យស៊ើបសួរជំនួសក្នុងសំណុំរឿង០០៣ និង០០៤ ភ្លាមបន្ទាប់ពី៖ (i) ការគាំទ្រលើកដំបូងរបស់គាត់ត្រូវបានដឹងឮជាសាធារណៈ និង (ii) អ្នកនាំពាក្យក្រសួងមហាផ្ទៃរបស់រាជរដ្ឋាភិបាលកម្ពុជា បានអះអាងម្តងហើយម្តងទៀតអំពីការជំទាស់របស់រដ្ឋាភិបាលកម្ពុជាចំពោះកិច្ចស៊ើបសួរថ្មីនេះ។ ចៅក្រម យូ ប៊ុនឡេង បានផ្តល់នូវអ្វីដែលអាចចាត់ទុកថា គ្រាន់តែជាយុត្តិកម្មក្លែងក្លាយចំពោះសកម្មភាពដ៏គួរឱ្យកត់សម្គាល់ពិតប្រាកដនេះ តែប៉ុណ្ណោះ។

ដូច្នេះចំពោះអ្នកអង្កេតការឥតលម្អៀងដែលមានព័ត៌មានគ្រប់គ្រាន់ (ឧទាហរណ៍អ្នកអង្កេតការដែលដឹងច្បាស់ពីក្តីបារម្ភដែលបានលើកយកពិភាក្សាខាងលើនេះ) វាហាក់បីដូចជាថាចៅក្រម យូ ប៊ុនឡេង គ្មានឆន្ទៈ ឬមិនអាចប្រកាន់ភ្ជាប់នូវការហាមឃាត់ដ៏តឹងរឹងមិនឱ្យទទួលយក ឬស្វែងរក "ការណែនាំពីរដ្ឋាភិបាល[២៦]របស់[គាត់]ឡើយ"។

១៨. ចៅក្រម យូ ប៊ុនឡេង ទំនងជាបានបកស្រាយមិនត្រឹមត្រូវពីលក្ខខណ្ឌនៃការទទួលយកបណ្តឹងតាមវិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង ដោយការបញ្ជាក់ថា "មូលហេតុនៃបណ្តឹង" មានន័យដូចគ្នានឹង "ភស្តុតាងបញ្ជាក់"[២៧]។ វិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង មិនបានចែងថា ភាគីត្រូវតែធ្វើ

---

[២៦] បណ្តឹងជំទាស់ចៅក្រម យូ ប៊ុនឡេង, កថាខណ្ឌ២០-២១ (ជើងទំព័រត្រូវបានលុបចោល)។

[២៧] ចម្លើយតប, កថាខណ្ឌ១១ ("អង្គហេតុជាចំបង ដែលបានលើកឡើងក្នុងបណ្តឹង")។

00600716



ពាក្យបណ្តឹងជំទាស់ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីបានដឹងពី "ភស្តុតាងគាំទ្រ" បណ្តឹងនោះទេ។ ផ្ទុយទៅវិញ វិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង បានចែងថា ពាក្យបណ្តឹងត្រូវធ្វើឡើងឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីបានដឹងអំពី "មូលហេតុនោះ"។

១៩. តាមធម្មតា វិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង នឹងតម្រូវឱ្យភាគីដាក់ពាក្យបណ្តឹងឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីបានដឹងអំពីភស្តុតាងបញ្ជាក់នៃបណ្តឹង[២៨]។ អង្គបុរេជំនុំជម្រះ ក៏យល់ឃើញផងដែរថា តាមវិធាន ៣៤(៣) នៃវិធានផ្ទៃក្នុង ភាគីអាចបានដឹងអំពី "ភស្តុតាងបញ្ជាក់" មួយចំនួន មុនពេលដែលខ្លួនបានដឹងអំពី "មូលហេតុនៃបណ្តឹងជំទាស់"។ អង្គបុរេជំនុំជម្រះបានកំណត់យុត្តិកម្ម និងវិសាលភាពនៃការបកស្រាយវិធាន ៣៤(៣) ក្នុងសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងរបស់ ខៀវ សំផន ដែលប្តឹងជំទាស់ចៅក្រម Lemonde ដូចខាងក្រោមនេះ៖

> ភាគីអាចបង្ហាញភស្តុតាងដែលទំនងជាមានលក្ខណៈខុសគ្នាកាលពីអតីតកាល ដែលត្រូវបានគេមើលឃើញថា ជាប់ពាក់ព័ន្ធផ្នែកបរិបទជាលើកដំបូង ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ថ្មីជាច្រើន។ ដើម្បីឱ្យស្ថិតនៅក្រោមវិសាលភាពនៃវិធានផ្ទៃក្នុង ៣៤(៣) ពួកគាត់បង្ហាញភស្តុតាងនេះភ្លាម នៅពេលដែលបរិបទមានភាពច្បាស់ជាក់ស្តែងចំពោះពួកគាត់ សម្រាប់ជាមូលដ្ឋាន ឬជាការគាំទ្រដល់មូលហេតុដែលពួកគាត់ស្នើឡើង[២៩]។

២០. អង្គបុរេជំនុំជម្រះ នឹងមិនទទួលស្គាល់ជានិច្ចជាកាលនូវ "ភស្តុតាងអតីតកាល" ដែលម្ចាស់បណ្តឹងបានដាក់ជូនក្នុងទម្រង់ជា "ភស្តុតាងបញ្ជាក់" នៃបណ្តឹងជំទាស់នោះទេ។ ផ្ទុយទៅវិញ លក្ខខណ្ឌស្តីពីពេលកំណត់ តាមវិធាន ៣៤(៣) អាចនឹងក្លាយទៅជាគ្មានន័យ និងគ្មានព្រំដែនកំណត់ថាតើអតីតកាលយូរប៉ុណ្ណាដែលម្ចាស់បណ្តឹងអាច ឬមិនអាចយកមកអះអាងបាន។ អង្គបុរេជំនុំជម្រះនឹងសម្រេច

---

[២៨] សាលដីកាជាសាធារណៈ ស្តីពីបណ្តឹងជំទាស់ជាបន្ទាន់របស់សហមេធាវីជនត្រូវចោទ នួន ជា ចំពោះលោកចៅក្រម ន័យ ធុល ដែលរង់ចាំសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នក្នុងករណី នួន ជា ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៨, ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស/(អ.ជ.ប០១), ឯកសារ C11/29, កថាខណ្ឌ៤ ("សាលដីកាលើបណ្តឹងជំទាស់របស់ នួន ជា ចំពោះចៅក្រម ន័យ ធុល")។

[២៩] សាលដីកាលើបណ្តឹងជំទាស់របស់ ខៀវ សំផន ចំពោះចៅក្រម Lemonde, កថាខណ្ឌ២០។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER E.C.C.C. E.T.C. PRÉLIMINAIRE

លើភាពអាចទទួលយកបាននៃភស្តុតាងអតីតកាល ទៅតាមមូលដ្ឋានករណីនីមួយៗ ដោយអនុលោមទៅតាមវិធានផ្ទៃក្នុង។

២១. អង្គបុរេជំនុំជម្រះ យល់ឃើញថាបណ្តឹងជំទាស់ដដែលបានចង្អុលបង្ហាញពីមូលហេតុមួយនៃបណ្តឹងជំទាស់ដូចតទៅនេះ៖ ចៅក្រម យូ ប៊ុនឡេង មិនមានឯករាជ្យភាពដែលជាតម្រូវការចាំបាច់សម្រាប់មុខតំណែងរបស់គាត់ជាសហចៅក្រមស៊ើបអង្កេត[៣០]។ អង្គបុរេជំនុំជម្រះ ក៏បានយល់ឃើញដែរថា បណ្តឹងជំទាស់បានបញ្ជាក់ពីទង្វើបីរបស់ចៅក្រម យូ ប៊ុនឡេង ជាភស្តុតាងបញ្ជាក់នៃមូលហេតុបណ្តឹងនេះ។

២២. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ម្ចាស់បណ្តឹងជំទាស់បានទទួលដំណឹងអំពីទង្វើទាំងបីនេះប្រហែលជាដប់មួយខែ[៣១], ប្រាំពីរខែ[៣២] និងប្រាំបីថ្ងៃ[៣៣] តាមលំដាប់ទង្វើនីមួយៗ មុនកាលបរិច្ឆេទដាក់ពាក្យបណ្តឹងនេះ។ បណ្តឹងបានបញ្ជាក់ថា "បណ្តឹងជំទាស់ត្រូវបានដាក់ភ្លាមបន្ទាប់ពីមេធាវី

---

[៣០] បណ្តឹងជំទាស់ចៅក្រម យូ ប៊ុនឡេង, កថាខណ្ឌ១, ១២-១៣, ១៧, ២០, ២៣, ២៥។

[៣១] លិខិតដំបូងរបស់សហចៅក្រមអន្តរជាតិ, ឯកសារ D122/5 ត្រូវបានដាក់នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩ និងបានជូនព័ត៌មានដល់មេធាវីរបស់ម្ចាស់បណ្តឹងនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩ ជាភាសាខ្មែរ និអង់គ្លេស។ លិខិតទីពីររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ, ឯកសារ D122/5/2 ត្រូវបានដាក់ជាភាសាខ្មែរនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ និងជាភាសាអង់គ្លេសនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ និងបានជូនដំណឹងដល់សហមេធាវីម្ចាស់បណ្តឹងជាភាសាខ្មែរនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ និងជាភាសាអង់គ្លេសនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩។

[៣២] ដីកាកោះសាក្សីចំនួន៦ ត្រូវបានដាក់ជាភាសាខ្មែរនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៩ និងជាភាសាអង់គ្លេស នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៩ និងថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩, និងបានជូនដំណឹងទៅសហមេធាវីម្ចាស់បណ្តឹង ជាភាសាខ្មែរនៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៩ និងជាភាសាអង់គ្លេសនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៩ និងថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩ (ចូរអានឯកសារ A296/1, A297/1, A298/1, A299/1, D136/2/1 និង D136/3/1)។

[៣៣] "សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេត" (ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១០) ត្រូវបានបញ្ជូនទៅឱ្យសហមេធាវីម្ចាស់បណ្តឹងនៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ អនុស្សរណៈផ្ទៃក្នុងរបស់សហចៅក្រមស៊ើបអង្កេត Marcel Lemonde (ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១០) ត្រូវបានផ្ញើជូនសហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និង អនុស្សរណៈផ្ទៃក្នុងរបស់សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង (ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០) ត្រូវបានផ្ញើជូនសហចៅក្រមស៊ើបអង្កេត Marcel Lemonde ។



អង្គបុរេជំនុំជម្រះ E.C.C.C. C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

ការពារក្តីបានដឹងពីទង្វើរបស់ចៅក្រម យូ ប៊ុនឡេង"[៣៤]។ មេធាវីការពារក្តីបានប្រើពាក្យថា "ងាយយល់ទេ"[៣៥] ដើម្បីបញ្ជាក់ថា ផលវិបាកនៃទង្វើទីបីដែលជាទង្វើចុងក្រោយរបស់ចៅក្រម យូ ប៊ុនឡេង នោះ គឺជាដើមចមនាំឱ្យខ្លួនសន្និដ្ឋានថា ខ្លួនមិនបានដឹងពីបរិបទនៃកង្វះឯករាជ្យភាពរបស់ចៅក្រម យូ ប៊ុនឡេង ដែលរងការចោទប្រកាន់ រួមទាំងភាពពាក់ព័ន្ធខាងបរិបទនៃទង្វើទីមួយ និងទីពីររបស់ចៅក្រម យូ ប៊ុនឡេង រហូតទាល់តែខ្លួនបានដឹងពីទង្វើទីបីរបស់ចៅក្រម យូ ប៊ុនឡេង។ ចៅក្រម យូ ប៊ុនឡេង មិនបានផ្តល់ជូនអង្គបុរេជំនុំជម្រះនូវមូលហេតុណាមួយ ដែលនាំឱ្យមានការសង្ស័យលើសេចក្តីសន្និដ្ឋានរបស់ម្ចាស់បណ្តឹងជំទាស់ទេឡើយ។

២៣. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ម្ចាស់បណ្តឹងជំទាស់មិនបានដាក់ពាក្យបណ្តឹងជំទាស់ចៅក្រម យូ ប៊ុនឡេង ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលណាដែលខ្លួនបានដឹងអំពីទង្វើទីពីររបស់ចៅក្រម យូ ប៊ុនឡេង នោះទេ។ ម្ចាស់បណ្តឹងជំទាស់ទើបតែបានដាក់ពាក្យបណ្តឹងជំទាស់ ក្រោយពីខ្លួនបានដឹងអំពីទង្វើទីបីរបស់ចៅក្រម យូ ប៊ុនឡេង តែប៉ុណ្ណោះ។ ផលវិបាកនៃការសន្និដ្ឋានរបស់ម្ចាស់បណ្តឹងជំទាស់មានន័យថា ក្នុងបរិបទនៃទង្វើទីមួយនិងទីពីរ អង្គបុរេជំនុំជម្រះត្រូវពិចារណាថាតើទង្វើទីបីរបស់ចៅក្រម យូ ប៊ុនឡេង បង្ហាញពីកង្វះឯករាជ្យ-ភាព និងកង្វះអនាគតិរបស់គាត់ដែរឬទេ។ ប្រសិនបើទង្វើទីបីរបស់ចៅក្រម យូ ប៊ុនឡេង មិនបង្ហាញពីកង្វះឯករាជ្យភាព និងកង្វះអនាគតិរបស់គាត់ទេ[៣៦] អង្គបុរេជំនុំជម្រះ មិនអាចសម្រេចទៅតាមពាក្យបណ្តឹងដោយផ្អែកតែលើមូលដ្ឋាននៃទង្វើទីមួយនិងទីពីររបស់ចៅក្រម យូ ប៊ុនឡេង បានឡើយ។

២៤. អង្គបុរេជំនុំជម្រះយល់ឃើញថាទង្វើទាំងបីរបស់ចៅក្រម យូ ប៊ុនឡេង ដែលម្ចាស់បណ្តឹងជំទាស់បានលើកឡើង គឺអាចចាត់ទុកជាភស្តុតាងបញ្ជាក់បាន។ អង្គបុរេជំនុំជម្រះក៏យល់ឃើញផងដែរថា ពាក្យបណ្តឹងអាចទទួលយកបាន តែក្នុងករណីដែលបានធ្វើឡើងឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលណាដែលភាគីបានដឹងអំពីមូលហេតុនេះ។

---

[៣៤] បណ្តឹងជំទាស់ចៅក្រម យូ ប៊ុនឡេង, កថាខណ្ឌ១៩។ សូមមើលផងដែរ ជើងទំព័រលេខ៥៧ នៃបណ្តឹងជំទាស់ ដូចដែលបានលើកឡើងជាថ្មីក្នុងកថាខណ្ឌ១៣ ខាងលើ នៃសេចក្តីសម្រេចនេះ។

[៣៥] បណ្តឹងជំទាស់ចៅក្រម យូ ប៊ុនឡេង, កថាខណ្ឌ២០។

[៣៦] ចូរអាន បណ្តឹងជំទាស់ចៅក្រម យូ ប៊ុនឡេង, កថាខណ្ឌ១។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C • C.E.T.C

## ខ. ភាពច្បាស់លាស់នៃពាក្យបណ្តឹង

២៥. ចៅក្រម យូ ប៊ុនឡេង ស្នើថាពាក្យបណ្តឹងមិនអាចទទួលយកបានទេ "ដោយសារ[ពាក្យបណ្តឹង] ផ្អែកលើអង្គហេតុដែលមានលក្ខណៈទូលំទូលាយ និងមិនច្បាស់លាស់"[៣៧]។ ដោយអនុលោមតាម វិធាន៣៤(៣) អង្គបុរេជំនុំជម្រះយល់ស្របជាមួយចៅក្រម យូ ប៊ុនឡេង ថាពាក្យបណ្តឹងជំទាស់មិនអាចទទួលយកបានទេ ប្រសិនបើពាក្យបណ្តឹងនោះមិន"បង្ហាញឱ្យច្បាស់អំពីមូលហេតុនៃបណ្តឹង"។

២៦. អង្គបុរេជំនុំជម្រះយល់ឃើញថា ការវាយតម្លៃថាតើពាក្យបណ្តឹងជំទាស់បង្ហាញច្បាស់ ឬមិនច្បាស់ពីមូលហេតុនៃបណ្តឹង ត្រូវធ្វើឡើងមុនការវាយតម្លៃទៅលើអង្គសេចក្តី ហើយខុសពីការវាយតម្លៃទៅលើអង្គសេចក្តីនៃពាក្យបណ្តឹង។ ដើម្បីបំពេញលក្ខខណ្ឌនៃភាពច្បាស់លាស់សម្រាប់គោលបំណងនៃការទទួលយកពាក្យបណ្តឹង ម្ចាស់បណ្តឹងត្រូវតែបង្ហាញមូលហេតុនៃបណ្តឹងជំទាស់ឱ្យបានច្បាស់លាស់គ្រប់គ្រាន់ ដើម្បីឱ្យអង្គបុរេជំនុំជម្រះ អាចធ្វើការត្រួតពិនិត្យលើអង្គសេចក្តីបានត្រឹមត្រូវ។ តាមខ្លឹមសារនៃកថាខណ្ឌ១៦ និង២១ ខាងដើមនៃសេចក្តីសម្រេចនេះ អង្គបុរេជំនុំជម្រះរកឃើញថាពាក្យបណ្តឹងបានបង្ហាញមូលហេតុនៃបណ្តឹងជំទាស់បានច្បាស់លាស់គ្រប់គ្រាន់។

## គ. ទំនាក់ទំនងរវាងសំណុំរឿង ០០២, ០០៣ និង០០៤

២៧. ចៅក្រម យូ ប៊ុនឡេង ទំនងជាផ្តល់យោបល់ថា ទង្វើពីរដំបូងនៅក្នុងភស្តុតាងបញ្ជាក់របស់ម្ចាស់បណ្តឹងមិនត្រូវទទួលយកបែបនេះទេ ព្រោះថា ទង្វើទាំងនោះខុសពីទង្វើទីបីត្រង់ថា ទង្វើពីរដំបូងទាក់ទងទៅនឹងសំណុំរឿង០០២ ចំណែកឯទង្វើទីបីទាក់ទងទៅនឹងសំណុំរឿង០០៣ និង០០៤[៣៨]។ តាមពិតទៅ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថាវិធាន ៣៤(៣) មិនតម្រូវថាភស្តុតាងបញ្ជាក់ត្រូវតែចេញពីសំណុំរឿងតែមួយនៅចំពោះមុខ អ.វ.ត.ក ឬសំណុំរឿងណាមួយនៅចំពោះមុខ អ.វ.ត.ក ទេ។ វិធាន៣៤(២) តម្រូវថាមូលហេតុនៃបណ្តឹងជំទាស់ ដោយរួមទាំងភស្តុតាងបញ្ជាក់ ត្រូវ"នៅក្នុង"ឬ"ទាក់ទង" សំណុំរឿង០០២។

---

[៣៧] ចម្លើយតប កថាខណ្ឌ១២

[៣៨] ចម្លើយតប កថាខណ្ឌ១១



PRE-TRIAL CHAMBER E.C.C.C * C.E.T.C CHAMBRE PRÉLIMINAIRE

**ឃ. ភាពដែលអាចទទួលយកបាននូវសារណាតប**

២៨. សារណាតបត្រូវបានដាក់ នៅក្នុងរយៈពេលកំណត់ដែលបានចែងក្នុងវិធាន ៣៤(៧) ដូច្នេះសារណាតបនេះ អាចទទួលយកបាន។

**ង. ភាពដែលអាចទទួលយកបាននូវសេចក្តីបន្ថែម និងការសង្កេតទៅលើសេចក្តីបន្ថែម**

២៩. ភស្តុតាងបញ្ជាក់បន្ថែម ខុសគ្នាពី "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះស្តីពីសំណើបន្ថែមរបស់ អៀង សារី ចំពោះពាក្យបណ្តឹងដិតចិត្តរបស់អៀង សារី ចំពោះចៅក្រម Marcel Lemonde និងសំណើសុំឱ្យមានសវនាការជាសាធារណៈ"[៣៩] ដោយសារភាគីមិនអាចទទួលបានភស្តុតាងបញ្ជាក់បន្ថែម(របាយការណ៍ OSJI) ដែលចែងក្នុងសេចក្តីបន្ថែម មុនពេលពាក្យបណ្តឹងត្រូវបានដាក់នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១០ បានទេ ព្រោះថារបាយការណ៍នោះចុះផ្សាយជាសាធារណៈនៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១០។ សេចក្តីបន្ថែមត្រូវបានដាក់នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០។ អង្គបុរេជំនុំជម្រះយល់ឃើញថាសេចក្តីបន្ថែមអាចទទួលយកបាន ដោយសារថាសំណើនេះត្រូវបានដាក់ទាន់ពេលវេលាកំណត់។

៣០. អង្គបុរេជំនុំជម្រះយល់ឃើញថា ការសង្កេតរបស់ចៅក្រម យូ ប៊ុនឡេង ទៅលើសេចក្តីបន្ថែមគឺអាចទទួលយកបានដោយសារសេចក្តីសង្កេតនេះត្រូវបានដាក់ទាន់ពេលវេលា ដែលកំណត់ដោយសេចក្តីសម្រេចលើសេចក្តីបន្ថែម។

## IV. ច្បាប់ជាធរមាន

**ក. មូលហេតុនៃបណ្តឹងដិតចិត្ត**

៣១. វិធាន ៣៤(២) នៃវិធានផ្ទៃក្នុងចែងថា៖

[៣៩] 00២/៩-១០-២00៩-អ.វ.ត.ក/អបជ(0១) ឯកសារលេខ៦ ERN 00411027-00411029។

ភាគីអាចធ្វើបណ្ដឹងជំទាស់ចំពោះចៅក្រម ក្នុងករណីណាមួយដែលចៅក្រមរូបនោះមាន ឬធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន ឬហិរញ្ញវត្ថុ ឬមានការពាក់ព័ន្ធដែលអាចធ្វើឱ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬអាចបង្កើតឱ្យមានភាពលម្អៀង។

៣២. នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនលើបណ្ដឹងជំទាស់របស់ នួន ជា ចំពោះចៅក្រម ន័យ ធុល អង្គបុរេជំនុំជម្រះបានកំណត់ច្បាប់សម្រាប់ពិចារណាលើអង្គសេចក្ដីនៃបណ្ដឹងជំទាស់ដូចតទៅនេះ៖

១៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា“ចំណុចចាប់ផ្ដើមនៃការសម្រេចលើការជំទាស់អំពី [ភាពលម្អៀង] គឺថា “មានការសន្មតទុកជាមុនអំពីភាពមិនលម្អៀងដែលមានចំពោះចៅក្រម” “ការសន្មតនេះ កើតចេញពីការធ្វើសច្ចាប្រណិធានចូលកាន់តំណែងរបស់ចៅក្រមនិងលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការតែងតាំងរបស់គាត់ [...]” និងដាក់បន្ទុកដ៏ធ្ងន់ចំពោះភាគី ដែលធ្វើបណ្ដឹងជំទាស់ក្នុងការដកចេញនូវការសន្មតទុកជាមុននេះ”។

១៦. អង្គបុរេជំនុំជម្រះយល់ឃើញថា ការសន្មតអំពីភាពអនាគតិនេះ គឺអនុវត្តចំពោះចៅក្រមទាំងអស់នៃ អ.វ.ត.ក។ មាត្រា៣.៣ នៃកិច្ចព្រមព្រៀងរវាងសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ (“កិច្ចព្រមព្រៀង”)ចែងថា:

> ចៅក្រមត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈ និងស្មារតីខ្ពស់ មិនលម្អៀង និងសុចរិត មានគុណសម្បត្តិ ដែលតម្រូវសម្រាប់តែងតាំងឱ្យបម្រើការងារក្នុងការិយាល័យតុលាការនៅក្នុងប្រទេសរបស់ខ្លួន។ ចៅក្រមត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនអាចទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតឡើយ។

[...]

១៧. មាត្រា១០ថ្មីនៃច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក ចែងថា “ចៅក្រមទាំងអស់នៃអង្គជំនុំជម្រះវិសាមញ្ញត្រូវតែងតាំងចេញពីក្នុងចំណោមចៅក្រម ដែលកំពុងបំពេញការងារបច្ចុប្បន្ន ឬទទួលការតែងតាំងបន្ថែម យោងតាមនីតិវិធីដែលមានស្រាប់សម្រាប់ការតែងតាំងនេះ ចៅក្រមទាំងអស់ត្រូវមានចរិតលក្ខណៈសីលធម៌ខ្ពស់ ស្មារតីអនាគតិ ភាពសុច្ចរិត និងជាពិសេសមានបទ

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

ពិសោធន៍ក្នុងច្បាប់ព្រហ្មទណ្ឌ ឬច្បាប់អន្តរជាតិរួមទាំងច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្សផង។ ចៅក្រមទាំងអស់ ត្រូវស្ថិតនៅឯករាជ្យក្នុងការបំពេញមុខនាទីរបស់ខ្លួន និងមិនត្រូវទទួលយក ឬស្វែងរកការណែនាំណាមួយពីរដ្ឋាភិបាលណាមួយឬប្រភពណាមួយដទៃទៀតឡើយ"។

[...]

១៩. ក្នុងបញ្ហានេះ អ្នកប្តឹងជំទាស់ត្រូវបង្ហាញភស្តុតាងឲ្យបានគ្រប់គ្រាន់ដល់អង្គបុរេជំនុំជម្រះ ដើម្បីឲ្យអង្គបុរេជំនុំជម្រះយល់ឃើញថា ចៅក្រមដែលត្រូវបានប្តឹងចោទប្រកាន់នោះអាចមានភាពលម្អៀងពិតប្រាកដមែន។ គឺមាននៅមានចំណុចជាមូលដ្ឋានច្រើនដែលត្រូវបំពេញដើម្បីជំទាស់ទៅនឹងការសន្មតជាមុននៃភាពអនាគតិ។

២០. យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ គឺមានលក្ខណៈដូចគ្នាក្នុងការធ្វើការវាយតម្លៃអំពីភាពលម្អៀង ដែលបានអនុវត្តក្នុងពេលនេះ។ សាលាឧទ្ធរណ៍របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) បានយល់ឃើញក្នុងករណីរបស់ហ្វូរ៉ាន់ហ្ស៊ីហ្សា (Furundzija) ថា:

> ចៅក្រមមួយរូបត្រូវបានចាត់ទុកថាមានភាពលម្អៀង ប្រសិនបើត្រូវបានរកឃើញថាមានសកម្មភាពលម្អៀងពិតប្រាកដមែន។ មានការលម្អៀងតាមរយៈការមើលឃើញពីខាងក្រៅ ប្រសិនបើ:
>
> - ចៅក្រមមួយរូបជាភាគីនៃរឿងក្តី ឬមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ឬទាក់ទងនឹងកម្មសិទ្ធិដែលបានមកពីរឿងក្តីនោះ ឬប្រសិនបើការសម្រេចសេចក្តីរបស់ចៅក្រមនឹងនាំឲ្យមានការគាំទ្រដល់រឿងក្តីមួយ ដែលរូបគាត់មានការពាក់ព័ន្ធជាមួយភាគីណាមួយនៃរឿងក្តីនោះ។ ក្នុងកាលៈទេសៈបែបនេះ ចៅក្រមរូបនោះ ត្រូវដកខ្លួនចេញពីរឿងក្តីនោះដោយស្វ័យប្រវត្តិ ឬ
> - ក្នុងកាលៈទេសៈដែលអាចនាំឲ្យមានការកត់សម្គាល់មួយដ៏សមហេតុផលមួយ និងមានព័ត៌មានត្រឹមត្រូវចំពោះការយល់ដឹងអំពីការលម្អៀងដោយសមហេតុផល។

យុត្តិសាស្ត្រនេះ ត្រូវបានអនុវត្តជាទូទៅដោយតុលាការអន្តរជាតិ។

២១. អ្នកសង្កេតការណ៍ឯករាជ្យក្នុងការវាយតម្លៃអំពីភាពលម្អៀងនេះ គឺត្រូវតែជា "បុគ្គលដែលមានព័ត៌មានគ្រប់គ្រាន់ហើយដឹងពីគ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់ រាប់បញ្ចូលទាំងប្រពៃណីនៃសុចរិតភាព និងភាពមិនលម្អៀងដែលបង្កើតបានជាផ្នែកមួយនៃមូលដ្ឋាន និងការវាយតម្លៃអំពីអង្គហេតុផងដែលថា ភាពអនាគតិ គឺជាករណីកិច្ចមួយក្នុងចំណោមករណីកិច្ចផ្សេងទៀត ដែលចៅក្រមគ្រប់រូបបានសច្ចាប្រណិធានថាត្រូវលើកតម្កើង"។ [ជើងទំព័រត្រូវបានលប់]

៣៣. នៅក្នុងសេចក្តីសម្រេចថ្មីៗនេះលើបណ្តឹងមិតចិត្តរបស់ អៀង សារី និង អៀង ធីរិទ្ធ ចំពោះចៅក្រម Marcel Lemonde អង្គបុរេជំនុំជម្រះបានកត់សម្គាល់ដូចតទៅនេះ៖

៣៨. *ក្រមសីលធម៌ចៅក្រម* របស់ អ.វ.ត.ក ផ្តល់ការណែនាំបន្ថែមទៀតត្រង់ចំណុចនេះ។ មាត្រា ២.១ ចែងថា 'ចៅក្រមត្រូវរក្សានូវភាពមិនលម្អៀង និងត្រូវធានាពីការបង្ហាញពីភាពមិនលម្អៀងនោះក្នុងការបំពេញមុខនាទីរបស់ខ្លួន'។ មាត្រា ៧.១ ចែងថា 'ចៅក្រមត្រូវអនុវត្តសិទ្ធិក្នុងការបញ្ចេញមតិ និងចូលរួមក្នុងកិច្ចការសាធារណៈណាដែលសមស្របជាមួយនឹងមុខនាទីនៃការិយាល័យរបស់ខ្លួន ហើយដែលមិនជះឥទ្ធិពល ឬទំនងជាអាចជះឥទ្ធិពលដល់ឯករាជ្យភាព និងភាពមិនលម្អៀងរបស់តុលាការ'។ ក្រមសីលធម៌ចៅក្រមរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិមានបទប្បញ្ញត្តិដូចគ្នានេះដែរ។

៣៩. មាត្រា ២.២ នៃ*គោលការណ៍ Bangalore ក្រមសីលធម៌មន្ត្រីតុលាការ* ចែងថាចៅក្រម 'ត្រូវតែធានាថាការប្រព្រឹត្តិរបស់ខ្លួនទាំងនៅក្នុង និងខាងក្រៅតុលាការ ត្រូវរក្សា និងបង្កើនទំនុកចិត្តរបស់សាធារណៈ វិជ្ជាជីវៈច្បាប់ និងគូរភាគីវិវាទ នៅក្នុងការរក្សាភាពមិនលម្អៀងរបស់ចៅក្រម និងរបស់តុលាការ'។ សេចក្តីអត្ថាធិប្បាយពីអត្ថបទនេះបន្តនិយាយថា 'ចៅក្រមគួរជៀសវាងការប្រើពាក្យ ឬការប្រព្រឹត្តដោយចេតនាដែលអាចនាំឱ្យគេយល់ថាគ្មានភាពអនាគតិ' ហើយជៀសវាង "ការសំដែងមតិដែលចៅក្រមអាចយល់ថាជា 'ការលេងដែលមិនបង្កអន្តរាយ' តែអាចធ្វើឱ្យបាត់បង់ភាពអនាគតិរបស់ចៅក្រម"។ [ជើងទំព័រត្រូវបានលុប]

៣៤. អង្គបុរេជំនុំជម្រះបានសម្រេចថា ចំណុចចាប់ផ្តើមនៃការសម្រេចចោទប្រកាន់ពីភាពលម្អៀង គឺនៅត្រង់ការសន្និដ្ឋានថាចៅក្រមមានអនាគតិ ហើយម្ចាស់បណ្តឹងមានបន្ទុកក្នុងការបង្ហាញថាចៅក្រមគ្មានអនាគតិ ដែលជាលក្ខខណ្ឌតម្រូវដ៏ខ្ពស់មួយ។ អង្គបុរេជំនុំជម្រះបានចែងថា៖

មូលហេតុនៃចំណុចចាប់ផ្តើមដ៏ខ្ពស់នេះ គឺថាខណៈពេលដែលភាពលម្អៀងពិតប្រាកដ ឬអាចមើលឃើញលើផ្នែកមួយរបស់ចៅក្រមណាម្នាក់ វាប៉ះពាល់ដល់ភាពសម្ងាត់នៃកិច្ចការរដ្ឋបាល វានឹងស្មើនឹងការគំរាមកំហែងលើផលប្រយោជន៍នៃកិច្ចការរដ្ឋបាលដែលមិនលម្អៀង និងយុត្តិធម៌ ប្រសិនបើចៅក្រមមានគុណសម្បត្តិគ្រប់គ្រាន់ផ្អែកលើមូលដ្ឋាននៃការចោទប្រកាន់អំពីភាពលម្អៀង ដែលគ្មានមូលដ្ឋាន និងគ្មានសំអាង។ សំណួរដែលសំខាន់ គឺថាតើទស្សនៃកង្វះភាពអនាគតិអាចជាយុត្តិកម្មយ៉ាងពិតប្រាកដដែរឬទេ? គ្រាន់តែមានអារម្មណ៍ ឬការសង្ស័យអំពីភាពលម្អៀង ដែលធ្វើដោយជនជាប់ចោទនោះ មិនមានលក្ខណៈគ្រប់គ្រាន់ទេ។ អ្វីដែលចាំបាច់នោះ គឺការយល់ដឹងអំពីភាពលម្អៀងយ៉ាងត្រឹមត្រូវ ដោយផ្អែកតាមការយល់ដឹងអំពីកាលៈទេសៈទាំងអស់ដែលពាក់ព័ន្ធ[៤០]។

៣៥. ដូចបានកត់សម្គាល់ខាងលើ មូលហេតុមួយនៃបណ្តឹងជំទាស់ចៅក្រម យូ ប៊ុនឡេង គឺការចោទប្រកាន់អំពីកង្វះភាពឯករាជ្យរបស់គាត់។ អ្នកដាក់ពាក្យបណ្តឹងស្នើអង្គបុរេជំនុំជម្រះពិចារណាទស្សនទាននៃភាពឯករាជ្យ និងអនាគតិ "រួមគ្នា" ពីព្រោះវាមាន "ទំនាក់ទំនងជិតស្និទ្ធនឹងគ្នា"[៤១]។ ម្ចាស់បណ្តឹងក៏ស្នើផងដែរថា "ខ្លួនមិនចាំបាច់បង្ហាញឱ្យឃើញច្បាស់ពីកង្វះខាតឯករាជ្យភាពជាក់ស្តែងដែលបង្កឱ្យមានការរំលោភសិទ្ធិទទួលបានការជំនុំជម្រះ ដោយយុត្តិធម៌បន្ថែមទៀតនោះទេ។ និយាយសាមញ្ញទៅ នៅពេលដែលឯករាជ្យភាពរបស់ចៅក្រមត្រូវបានសង្ស័យ ចៅក្រមរូបនោះត្រូវតែបានដកចេញពីមុខតំណែង"[៤២]។

៣៦. អង្គបុរេជំនុំជម្រះរកឃើញថា ភស្តុតាងបញ្ជាក់របស់ម្ចាស់បណ្តឹងមិនបានបង្ហាញច្បាស់ពីកង្វះឯករាជ្យភាព ឬអនាគតិរបស់ចៅក្រម យូ ប៊ុនឡេង ឡើយ។ ដូច្នេះហើយ អង្គបុរេជំនុំជម្រះ

---

[៤០] សេចក្តីសម្រេចលើសំណើរបស់ជនត្រូវចោទ អៀង សារី សុំឱ្យមានវិធានការសមរម្យពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍មួយចំនួន ដែលធ្វើឡើងដោយ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានតតាំងនឹងឯករាជ្យភាពរបស់ចៅក្រមអង្គបុរេជំនុំជម្រះ ចៅក្រម Katinka LAHUIS និងចៅក្រម Rowan DOWNING ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, ០០២/២០-១០-២០០៩-អ.វ.ត.ក/ក.ស.ច.ស/(អ.ជ.ប០៣), ឯកសារលេខ៥, ERN 00404595-00404601 កថាខណ្ឌ៧ ("សេចក្តីសម្រេចលើសំណើរបស់ជនត្រូវចោទ អៀង សារី សុំឱ្យមានវិធានការសមរម្យ") (ជើងទំព័រត្រូវបានលុប)។

[៤១] បណ្តឹងជំទាស់ចៅក្រម យូ ប៊ុនឡេង, កថាខណ្ឌ១៧។

[៤២] បណ្តឹងជំទាស់ចៅក្រម យូ ប៊ុនឡេង, កថាខណ្ឌ២៣ (គូសបញ្ជាក់បន្ថែមក្នុងច្បាប់ដើម)។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

យល់ឃើញថា មិនមានការចាំបាច់ក្នុងការពិនិត្យទំនាក់ទំនងរវាងឯករាជ្យភាព និងអនាគតិដោយអនុលោមតាមលក្ខណៈវិនិច្ឆ័យដែលមានដើម្បីសម្រេចបណ្តឹងនេះតាមវិធាន ៣៤(២) ទេ។

## ខ. ការចោទប្រកាន់អំពីភាពលម្អៀងដោយផ្អែកលើសេចក្តីសម្រេចរបស់តុលាការ

៣៧. អង្គបុរេជំនុំជម្រះកាលពីមុនបានសង្កេតឃើញដូចតទៅនេះ៖

> អង្គបុរេជំនុំជម្រះ 'មានភារកិច្ចដើម្បីត្រួតពិនិត្យមើលខ្លឹមសារនៃសេចក្តីសម្រេចរបស់តុលាការ ដែលបានលើកឡើងថាជាភស្តុតាងបង្ហាញពីភាពលម្អៀង' និង...'គោលបំណងនៃការពិនិត្យឡើងវិញ មិនមែនដើម្បីស្វែងរកវិការៈនោះទេ ប៉ុន្តែដើម្បីកំណត់សម្រេចថា បើសិនមានវិការៈ តើវិការៈនោះបង្ហាញថា ចៅក្រមមួយរូប ឬច្រើនរូបមានភាពលម្អៀងពិតប្រាកដដែរឬទេ ឬបង្ហាញថា មានភាពទំនងថាមានភាពលម្អៀង ដែលបានផ្អែកលើលក្ខណៈវិនិច្ឆ័យសត្យានុម័តដែរឬទេ'... ប្រសិនបើមានវិការៈលើគំនិតសំខាន់នៃច្បាប់មិនមានលក្ខណៈគ្រប់គ្រាន់នោះទេ អ្វីដែលត្រូវធ្វើការបង្ហាញគឺថា ឬនឹងត្រូវបានយល់ឃើញយ៉ាងសមហេតុផលថា ការសម្រេចគឺអាចកើតឡើងដោយសារការរៀបចំជាមុនប្រឆាំងនឹងអ្នកដាក់ពាក្យបណ្តឹង ហើយការសម្រេចនោះមិនពាក់ព័ន្ធទៅនឹងការអនុវត្តច្បាប់យ៉ាងពិតប្រាកដ (ដែលអាចមានការបកស្រាយដែលអាចមានលើសពីមួយ) ឬពាក់ព័ន្ធទៅនឹងការវាយតម្លៃទៅលើអង្គហេតុនានាដែលពាក់ព័ន្ធនោះទេ[៤៣]។

៣៨. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញផងដែរថា ការងាររបស់ចៅក្រមគឺចេញសេចក្តីសម្រេច ហើយប្រាកដជាមានភាគីណាមួយ មានការមិនពេញចិត្តនឹងសេចក្តីសម្រេចនោះដោយជៀសមិនរួច។ ចំណុចនេះមិនបង្កើតបានជាមូលដ្ឋាននៃការប្តឹងជំទាស់ចៅក្រមនោះទេ ក៏ប៉ុន្តែជាមូលដ្ឋាននៃការប្តឹងឧទ្ធរណ៍ ឬនៃកិច្ចខិតខំប្រឹងប្រែងក្នុងការរកដំណោះស្រាយផ្លូវច្បាប់ ក្នុងដំណាក់កាលមុនអង្គសេចក្តី នៅដំណាក់កាលជំនុំជម្រះ និងនៅដំណាក់កាលប្តឹងឧទ្ធរណ៍នៃកិច្ចដំណើរការនីតិវិធី[៤៤]។

---

[៤៣] សាលដីកាលើបណ្តឹងជំទាស់ចៅក្រមរបស់ ខៀវ សំផន ចំពោះចៅក្រម Lemonde, កថាខណ្ឌ៣៤, សម្រង់ពី *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Arsene Shalom Ntahobali*, ICTR-97-21-T, "សេចក្តីសម្រេចលើបណ្តឹងជំទាស់ចៅក្រម" (Bureau), ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០៦, កថាខណ្ឌ១២។

[៤៤] សាលដីកាលើបណ្តឹងជំទាស់ចៅក្រមរបស់ ខៀវ សំផន ចំពោះចៅក្រម Lemonde, កថាខណ្ឌ៣៥ (ជើងទំព័រត្រូវបានលុប)។

## គ. សេចក្ដីថ្លែងការណ៍ដែលដកស្រង់នៅក្នុងសារព័ត៌មាន

៣៩. នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនលើសំណើរបស់ជនត្រូវចោទ អៀង សារី សុំឲ្យមានវិធានការសមរម្យ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា សុន្ទរកថាមួយដែលធ្វើដោយសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលត្រូវបានរាយការណ៍នៅក្នុងសារព័ត៌មាន បានចោទប្រកាន់អំពីអន្តរាគមន៍ធ្វើឡើងដោយរដ្ឋាភិបាលបរទេស ពាក់ព័ន្ធទៅនឹងចៅក្រមអន្តរជាតិ នៃអង្គជំនុំជម្រះវិសាមញ្ញទាំងអស់ ប៉ុន្តែមិនបាននិយាយដល់ទង្វើជាក់លាក់របស់លោកចៅ ក្រម Downing និងលោកស្រីចៅក្រម Lahuis នោះទេ។ អង្គបុរេជំនុំជម្រះបានយល់ឃើញថា “ទោះបីជាបានទទួលស្គាល់ផ្នែកដែលបានរៀបរាប់នៅក្នុងសំណើសុំថាជាកំណត់ហេតុពិតប្រាកដ នៃសុន្ទរកថារបស់សម្ដេចនាយករដ្ឋមន្ត្រីក៏ដោយ ក៏ផ្នែកទាំងនោះមិនមានតម្លៃជាភស្តុតាងដែលអាចជឿជាក់បាន និងគ្រប់គ្រាន់ដែលបង្ហាញថាចៅក្រមទាំងពីររូបនេះ មានភាពលម្អៀងជាសត្យានុម័ត ឬជាអត្តនោម័តនោះឡើយ”[៤៥]។

## V. ការពិចារណាលើអង្គសេចក្ដី

## ក. ការអះអាងទូទៅប្រឆាំងនឹងតុលាការកម្ពុជា

៤០. ម្ចាស់បណ្ដឹងបានលើកឡើងថា តុលាការកម្ពុជាទាំងមូលទទួលរងការជ្រៀតជ្រែកពីសំណាក់អង្គការនីតិប្រតិបត្តិ និងកង្វះឯករាជ្យភាព ឬការយល់ឃើញថាខ្វះឯករាជ្យភាព[៤៦]។ សេចក្ដីបន្ថែមលើកឡើងថា អង្គបុរេជំនុំជម្រះគួរផ្ដល់ “ការពិចារណាឲ្យបានសមស្រប”[៤៧] ចំពោះរបាយការណ៍របស់ OSJI កាលពីខែកក្កដា ឆ្នាំ២០១០។ សេចក្ដីបន្ថែមបានបញ្ជាក់ថា៖

> ជាពិសេសរបាយការណ៍នេះបានលើកឡើងពី (ក្នុងចំណោមបញ្ហាដទៃទៀត): (i) កង្វះឯករាជ្យភាពនៃប្រព័ន្ធតុលាការកម្ពុជា (ii) ពុំមានការបែងចែកអំណាចឲ្យដាច់ចេញពីគ្នា រវាងអំណាចតុលាការ និងអំណាចនីតិប្រតិបត្តិ នៅព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ននេះ (iii) មានករណីការជ្រៀតជ្រែកនយោបាយជាច្រើនទៅសាលាក្ដីមួយនេះ និង (iv) ភាពលំបាកនៃការធ្វើ

---

[៤៥] សេចក្ដីសម្រេចលើសំណើរបស់ជនត្រូវចោទ អៀង សារី សុំឲ្យមានវិធានការសមរម្យ, កថាខណ្ឌ១១។

[៤៦] ឧទាហរណ៍, បណ្ដឹងជំទាស់ចៅក្រម យូ ប៊ុនឡេង, កថាខណ្ឌ១-២។

[៤៧] សេចក្ដីបន្ថែមលើបណ្ដឹងជំទាស់, កថាខណ្ឌ៨។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRELIMINAIRE

ឱ្យប្រសើរឡើងនៃការជ្រៀតជ្រែកនេះ ដោយសារតែក្របខណ្ឌនីតិវិធី ដែលបង្កើតឡើងដោយកិច្ចព្រមព្រៀង។

. . .

ដោយពិចារណាទៅលើតួនាទីដ៏យូរអង្វែងជាអ្នកអង្កេតការឯករាជ្យ និងមិនលម្អៀងនៃដំណើរការនីតិវិធីនៅ អវតក OSJI គួរតែត្រូវបានគេចាត់ទុកថាជាអ្នកអង្កេតការមិនលម្អៀងរបស់សាលាក្តីខ្មែរក្រហម ព្រោះ OSJI គឺ "ជាអង្គការមួយដែលមានព័ត៌មានពេញលេញ និងបានដឹងឮរាល់កាលៈទេសៈដែលពាក់ព័ន្ធទាំងអស់ រួមទាំងប្រពៃណីនៃសុចរិតភាព និងភាពមិនលម្អៀង ដែលបង្កើតជាផ្នែកមួយនៃសារធាតុ និងបានវាយតម្លៃផងដែរ អំពីកត្តានានាដែលថាភាពមិនលម្អៀងគឺជាកាតព្វកិច្ចមួយក្នុងចំណោមកាតព្វកិច្ចជាច្រើនទៀត ដែលចៅក្រមត្រូវតែប្រកាន់ខ្ជាប់"[៤៨]។

៤១. កាលពីមុន អង្គបុរេជំនុំជម្រះបានសម្រេចនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងជំទាស់របស់ជនត្រូវចោទ នួន ជា ចំពោះចៅក្រម ន័យ ថុល ដូចតទៅនេះ៖

ភស្តុតាងភាគច្រើនដែលបង្កើតឡើងដោយមេធាវីការពារក្តី គឺជាឯកសារអត្ថាធិប្បាយរបស់ភាគីទីបី និងពាក់ព័ន្ធជាទូទៅលើការកត់សម្គាល់ស្តីពីការចោទប្រកាន់អំពីសមត្ថកិច្ច និងហេតុផលដែលជំរុញទឹកចិត្តនៃតុលាការកម្ពុជាទាំងមូលតែម្តង និងមិនមែនតែចំពោះតែលោកចៅក្រមន័យ ថុល តែម្នាក់ប៉ុណ្ណោះទេ។ ការកត់សម្គាល់ជាទូទៅ និងការអះអាងនេះ គឺគ្មានភស្តុតាងបញ្ជាក់អំពីភាពលម្អៀងរបស់លោកចៅក្រម ន័យ ថុល ក្នុងរឿងក្តីលោក នួន ជា ទេ[៤៩]។

៤២. អង្គបុរេជំនុំជម្រះឯកភាពជាមួយចៅក្រម យូ ប៊ុនឡេង ដែលថាការចោទប្រកាន់របស់ម្ចាស់បណ្តឹងប្រឆាំងនឹងតុលាការកម្ពុជា គឺ"មានលក្ខណៈទូលំទូលាយពេក ដែលមិនអាចយកមកធ្វើជាមូលដ្ឋាននៃបណ្តឹងជំទាស់តែសោះ"[៥០] ពីព្រោះ "ជាគោលការណ៍នៃបណ្តឹងជំទាស់ រាល់បណ្តឹងជំទាស់

---

[៤៨] សេចក្តីបន្ថែមលើបណ្តឹងជំទាស់, កថាខណ្ឌ២, ៨ (ជើងទំព័រត្រូវបានលុបចោល)។

[៤៩] សាលដីកាលើបណ្តឹងជំទាស់របស់ នួន ជា ចំពោះចៅក្រម ន័យ ថុល, កថាខណ្ឌ៣២។

[៥០] ចម្លើយតប, កថាខណ្ឌ១៣។

ចៅក្រមណាមួយ គឺត្រូវតែលើកពីភស្តុតាងទាក់ទងនឹងមូលហេតុចំពោះចៅក្រមនោះផ្ទាល់"[៥១]។ អង្គបុរេជំនុំជម្រះរកឃើញថា ការអះអាងទូទៅនៅក្នុងពាក្យបណ្តឹង និងសេចក្តីបន្ថែម ដោយរួមទាំងរបាយការណ៍របស់ OSJI កាលពីខែកក្កដា ឆ្នាំ២០១០ ប្រឆាំងនឹងតុលាការកម្ពុជា មិនបញ្ជាក់ថា ជាពិសេសចៅក្រម យូ ប៊ុនឡេង គ្មានឯករាជ្យភាព ឬអនាគតិទេ ហេតុដូច្នេះហើយមិនប្រឆាំងនឹងការសន្មតនៃអនាគតិរបស់ចៅក្រម យូ ប៊ុនឡេង ដែលកើតចេញការតែងតាំងគាត់ជាមន្ត្រីតុលាការនៅ អ.វ.ត.ក ឡើយ។

**ខ. ឧទ្ទិទីមួយរបស់ចៅក្រម យូ ប៊ុនឡេង**

**សារណារបស់ភាគី**

៤៣. ម្ចាស់បណ្តឹងលើកឡើងថា ការជំទាស់របស់ចៅក្រម យូ ប៊ុនឡេង "មិនព្រមចុះហត្ថលេខាលើលិខិតរបស់ កសចស ផ្ញើទៅ [redacted] ដើម្បីសុំសម្ភាស [redacted] គឺស្រប គ្នានឹងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីទប់ស្កាត់ការបញ្ជូនលិខិតនោះទៅ [redacted]"[៥២]។ ពាក្យបណ្តឹងក៏ថ្លែងផងដែរថា "ព្រឹត្តិការណ៍នានាជុំវិញកិច្ចខិតខំប្រឹងប្រែងរបស់ កចសច បានបង្ហាញយ៉ាងច្បាស់ថា [redacted] ត្រូវបានគេរាំងមិនឱ្យ [redacted] បញ្ចេញទស្សនៈផ្ទាល់របស់ទ្រង់ទាក់ទងនឹងបញ្ហាដែលលើកឡើងដោយមន្ត្រីរដ្ឋាភិបាល"ទោះបីជា ដូចដែលម្ចាស់បណ្តឹងទទួលស្គាល់ថា "រាជរដ្ឋាភិបាលមិនដែលបញ្ចេញជាសាធារណៈពីជំហររបស់ខ្លួន ទាក់ទងនឹងការសម្ភាសន៍ [redacted] (ឥឡូវនេះវាទំនងជាមិនអាចកើតឡើងនោះទេ)"[៥៣]។

៤៤. ចៅក្រម យូ ប៊ុនឡេង ថ្លែងនៅក្នុងចម្លើយតបរបស់គាត់ដូចតទៅនេះ៖

> ខ្ញុំបានបង្ហាញនូវទឡ្ហីករណ៍ជាច្រើន ដូចមានក្នុងសំអាងហេតុដីកាសម្រេចលើសំណើសុំកោះហៅសាក្សីដែលបានដាក់ដោយក្រុមមេធាវីការពារក្តី នួន ជា និង អៀង សារី រួចហើយ

---

[៥១] ចម្លើយតប, កថាខណ្ឌ១៥។ *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើរបស់ជនត្រូវចោទ អៀង សារី សុំឱ្យមានវិធានការសមរម្យ, កថាខណ្ឌ១១។

[៥២] បណ្តឹងជំទាស់ចៅក្រម យូ ប៊ុនឡេង, កថាខណ្ឌ២១(ក)។

[៥៣] បណ្តឹងជំទាស់ចៅក្រម យូ ប៊ុនឡេង, កថាខណ្ឌ៥ (ជើងទំព័រត្រូវបានលុប)។

ហើយដីកាសម្រេចទាំងនោះ អង្គបុរេជំនុំជម្រះក៏បានជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់មេធាវីជនត្រូវចោទរួចហើយដែរ ពិសេសគឺបណ្តឹងឧទ្ធរណ៍របស់មេធាវី នួន ជា[៥៤]។

. . .

ខ្ញុំសូមគូសបញ្ជាក់ថា ការសម្រេចចិត្តក្នុងការសម្រេចស្តាប់ចម្លើយសាក្សីដែលមានសារៈសំខាន់សម្រាប់ស្វែងរកការពិត ឬអត់នោះគឺផ្អែកទៅលើការវាយតម្លៃដោយឥស្សរចិត្តរបស់សហចៅក្រមស៊ើបសួរ ដែលការវាយតម្លៃនេះមិនអាចយល់ស្របគ្នារហូតនោះឡើយ។ ហេតុដូចនេះហើយ ក្នុងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងច្បាប់ អ.វ.ត.ក ក៏ដូចជាវិធានផ្ទៃក្នុង បានរំពឹងទុកជាស្រេចអំពីអំណាចឆន្ទានុសិទ្ធិក្នុងការសម្រេចចិត្តរបស់ចៅក្រមលើចំណាត់ការនីតិវិធី។ ដូច្នេះ មានចំណុចខ្លះត្រូវតែមានការខ្វែងយោបល់គ្នាជៀសមិនផុត ដើម្បីជាប្រយោជន៍នៃសំណុំរឿង... ជារួមអ្វីដែលសំខាន់គឺថាសហចៅក្រមនីមួយៗអនុវត្តទៅតាមគោលការណ៍ច្បាប់ជាធរមាន[៥៥]។

## ការពិចារណារបស់អង្គបុរេជំនុំជម្រះ

៤៥. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា មិនមានកន្លែងណាមួយនៅក្នុងពាក្យបណ្តឹងដែលម្ចាស់បណ្តឹងព្យាយាមពន្យល់ថា តើសេចក្តីសម្រេចពីមុនរបស់ចៅក្រម យូ ប៊ុនឡេង ក្នុងការមិនចុះហត្ថលេខាលើលិខិតនោះ ទាក់ទងយ៉ាងដូចម្តេចទៅនឹង"ការជ្រៀតជ្រែកលើកិច្ចប្រឹងប្រែងកោះអញ្ជើញ[redacted]ដើម្បីធ្វើការសម្ភាសន៍"[៥៦]។ ពាក្យបណ្តឹងគ្រាន់តែពោលថា សេចក្តីសម្រេចរបស់ចៅក្រម យូ ប៊ុនឡេង និង"ការជ្រៀតជ្រែកយ៉ាងសកម្ម" គឺ "ស៊ីសង្វាក់គ្នា"។ អង្គបុរេជំនុំជម្រះបដិសេធការអះអាងដែលគ្មានមូលដ្ឋាននេះដោយយោងទៅរកច្បាប់យុត្តិសាស្ត្ររបស់ខ្លួនដូចតទៅនេះ៖

---

[៥៤] ជើងទំព័រ១៧-១៨ នៅក្នុង ដីកាសម្រេចលើសំណើសុំកោះហៅសាក្សី ដែលដាក់ដោយក្រុមមេធាវីការពារក្តី នួន ជា និង អៀង សារី, ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១០, ០០២-១៩-០៩-២០០៧-អវតក-ក.ស.ច.ស, ឯកសារ D314 និង សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី និងលោក នួន ជា ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសំណើសុំឲ្យកោះហៅសាក្សី, ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០, ០០២-១៩-០៩-២០០៧-អវតក-ក.ស.ច.ស(អ.ជ.ប៥០ និង៥១) ឯកសារD314/1/8, D314/2/7។

[៥៥] ចម្លើយតប, កថាខណ្ឌ១៩-២០។

[៥៦] បណ្តឹងជិតចិត្តចៅក្រម យូ ប៊ុនឡេង, កថាខណ្ឌ៥។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

អង្គបុរេជំនុំជម្រះមិនមានកាតព្វកិច្ចប៉ាន់ស្មានអំពីមូលហេតុដែលមានតែចៅក្រម Lemonde ប៉ុណ្ណោះដែលបានចុះហត្ថលេខាលើ [redacted]។ ចំពោះការខ្វះការសហការគ្នារវាងសហចៅក្រមស៊ើបអង្កេត ឬការខ្វែងយោបល់គ្នារវាងចៅក្រមនោះ អង្គបុរេជំនុំជម្រះថែមទាំងមិនអាចទាញសេចក្តីសន្និដ្ឋានលើភាពអនាគតិ[ឬឯករាជ្យភាព] របស់ចៅក្រមទៅទៀត[៥៧]។

## គ. ទង្វើទីពីររបស់ចៅក្រម យូ ប៊ុនឡេង

### សារណារបស់ភាគី

៤៦. ទង្វើទីពីររបស់ចៅក្រម យូ ប៊ុនឡេង ដែលម្ចាស់បណ្តឹងអះអាងថា ជាភស្តុតាងបញ្ជាក់ មានខ្លឹមសារដូចតទៅនេះ៖

> ការជំទាស់របស់ចៅក្រម យូ ប៊ុនឡេង មិនព្រមចុះហត្ថលេខាលើដីការបស់ កចសច ដើម្បីកោះអញ្ជើញមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់កម្ពុជាប្រាំមួយរូប គឺស្របគ្នាទៅនឹងការថ្លែងរបស់នាយករដ្ឋមន្ត្រីកម្ពុជា(ដែលថារូបលោកផ្ទាល់បានទប់ស្កាត់មិនឱ្យមានការផ្តល់សក្ខីកម្មពីបុគ្គលមួយចំនួន) និងការថ្លែងពីសំណាក់រដ្ឋមន្ត្រីក្រសួងព័ត៌មានកម្ពុជា (ដែលថា យោងទៅតាមរាជរដ្ឋាភិបាលកម្ពុជា បុគ្គលប្រាំមួយរូបដែលត្រូវកោះហៅនោះ មិនគួរផ្តល់សក្ខីកម្មឡើយ)[៥៨]។

៤៧. ចៅក្រម យូ ប៊ុនឡេង បានឆ្លើយតបថា "[redacted]"[៥៩]។ ចៅក្រម យូ ប៊ុនឡេង ក៏ថ្លែងផងដែរថា ប្រសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រីនាថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៩ មិនត្រូវបានផ្សព្វផ្សាយជាសាធារណៈក្នុងប្រព័ន្ធសារព័ត៌មាន រហូតដល់ថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៩[៦០]។

---

[៥៧] សាលដីកាលើបណ្តឹងមិនទុកចិត្តរបស់ នួន ជា ពោះចៅក្រម Lemonde, កថាខណ្ឌ២២។

[៥៨] បណ្តឹងមិនទុកចិត្តចៅក្រម យូ ប៊ុនឡេង, កថាខណ្ឌ២១(ខ)។

[៥៩] ចម្លើយតប, កថាខណ្ឌ២១។

[៦០] ចម្លើយតប, ជើងទំព័រ២៣។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

## ការពិចារណាដោយអង្គបុរេជំនុំជម្រះ

៤៨. ម្ចាស់បណ្តឹងទទួលស្គាល់ថា ការលើកឡើងរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន គឺត្រូវបានដកស្រង់សំដីក្នុងកាសែតភ្នំពេញប៉ុស្តិ៍ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩ "គឺរយៈពេលពីរសប្តាហ៍ក្រោយ[ការដាក់ដីកាកោះអញ្ជើញសាក្សីទាំងប្រាំមួយរូប]"[៦១]។ ដូចគ្នានឹងសកម្មភាពទីមួយរបស់ចៅក្រម យូ ប៊ុនឡេង ដែរ ក្រៅពីការព្យាយាមភ្ជាប់សេចក្តីសម្រេចពីមុនរបស់ចៅក្រម យូ ប៊ុនឡេង ទៅនឹងការលើកឡើងរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន ដែលត្រូវបានដកស្រង់សំដីក្នុងសារព័ត៌មានជាបន្តបន្ទាប់ ម្ចាស់បណ្តឹងគ្រាន់តែអះអាងថា ការលើកឡើងទាំងពីរ គឺ"ស៊ីសង្វាក់គ្នា"។ ដូច្នេះហើយ ដោយមានមូលហេតុដូចគ្នានឹងខាងលើដែរ អង្គបុរេជំនុំជម្រះបដិសេធនូវសេចក្តីសន្និដ្ឋានរបស់ម្ចាស់បណ្តឹងទាក់ទងទៅនឹងការលើកឡើងរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន ដែលត្រូវបានដកស្រង់សំដីក្នុងសារព័ត៌មាន។

៤៩. ទោះបីជាប្រសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រីដែលត្រូវបានដកស្រង់ ធ្វើឡើងនៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០០៩[៦២]ក៏ដោយ ក៏ម្ចាស់បណ្តឹងមិនបានផ្តល់ហេតុផលអ្វីឲ្យដើម្បីតទល់នឹងចម្លើយតបរបស់ចៅក្រម យូ ប៊ុនឡេង ថា "ការមិនឯកភាពរបស់គាត់នៅក្នុងការកោះហៅសាក្សីនោះត្រូវបានធ្វើឡើងមុនពេលដែលមានការប្រកាសជាសាធារណៈរបស់ថ្នាក់ដឹកនាំនោះទៅទៀត ... [redacted]"[៦៣]។ អ្នកដាក់ពាក្យបណ្តឹងបានទទួលស្គាល់ច្បាស់ថា "វាមិនច្បាស់ក្នុងអត្ថបទសុន្ទរកថា (i) សាក្សីជាក់លាក់មួយណាដែលនាយករដ្ឋមន្ត្រីជំទាស់ និង (ii) តើនាយករដ្ឋមន្ត្រីរូបនេះចាត់ការតាមនីតិវិធីយ៉ាងដូចម្តេចក្នុងការជំទាស់នេះ"[៦៤]។ ដូច្នេះ សេចក្តីសន្និដ្ឋានរបស់ម្ចាស់បណ្តឹងទាក់ទងទៅនឹងទង្វើទីពីររបស់ចៅក្រម យូ ប៊ុនឡេង ត្រូវបានបដិសេធ។

---

៦១ បណ្តឹងជិតចិត្តចៅក្រម យូ ប៊ុនឡេង, កថាខណ្ឌ៤ និង ជើងទំព័រ១៣។

៦២ សំណើសុំបំពេញកិច្ចស៊ើបសួរ, ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, ឯកសារD254, កថាខណ្ឌ៦; ចម្លើយតប, ជើងទំព័រ២៣។

៦៣ ចម្លើយតប, កថាខណ្ឌ២១។

៦៤ សំណើសុំបំពេញកិច្ចស៊ើបសួរ, ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩, ឯកសារD254, កថាខណ្ឌ៦។ *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើរបស់ជនត្រូវចោទ អៀង សារី សុំឲ្យមានវិធានការសមរម្យ, កថាខណ្ឌ១១។

## ឃ. ទង្វើទីបីរបស់ចៅក្រម យូ ប៊ុនឡេង

## សារណារបស់គាត់

៥០. ទង្វើទីបី និងជាសកម្មភាពចុងក្រោយរបស់ចៅក្រម យូ ប៊ុនឡេង ដែលម្ចាស់បណ្ដឹងអះអាងថាជាភស្តុតាងបញ្ជាក់ពីកង្វះឯករាជ្យភាពរបស់គាត់និងបានចោទប្រកាន់ថា "ទង្វើយ៉ាងច្បាស់ក្រឡែត"។ ម្ចាស់បណ្ដឹងបានអះអាងថា៖

> [ចៅក្រម យូ ប៊ុនឡេង] "មិនព្រមចុះហត្ថលេខា" លើដីកាចាត់ឱ្យស៊ើបសួរជំនួសក្នុងសំណុំរឿង០០៣ និង០០៤ ភ្លាមបន្ទាប់ពី៖ (i) ការគាំទ្រលើកដំបូងរបស់គាត់ត្រូវបានដឹងឮជាសាធារណៈ និង (ii) អ្នកនាំពាក្យក្រសួងមហាផ្ទៃរបស់រាជរដ្ឋាភិបាលកម្ពុជា បានអះអាងម្ដងហើយម្ដងទៀតអំពីការជំទាស់របស់រដ្ឋាភិបាលកម្ពុជាចំពោះកិច្ចស៊ើបសួរថ្មីនេះ។ ចៅក្រម យូ ប៊ុនឡេង បានផ្ដល់នូវអ្វីដែលអាចចាត់ទុកថា គ្រាន់តែជាយុត្តិកម្មក្លែងក្លាយចំពោះសកម្មភាពដ៏គួរឱ្យកត់សម្គាល់ពិតប្រាកដនេះតែប៉ុណ្ណោះ[៦៥]។

៥១. ម្ចាស់បណ្ដឹងពឹងផ្អែកលើអត្ថបទសារព័ត៌មានក្នុងការលើកឡើងថា "ជាងមួយទស្សវត្សរ៍មកនេះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសម្ដងហើយម្ដងទៀត 'ថា [អវតក] មិនត្រូវចោទប្រកាន់ជនសង្ស័យឱ្យលើសពីប្រាំនាក់នេះទេ... គោលនយោបាយជាចំហនេះ ត្រូវបានបង្ហាញឱ្យឃើញជាហូរហែ និងជាចំហដោយមន្ត្រីជាន់ខ្ពស់នៃរដ្ឋាភិបាល ព្រមទាំង 'មន្ត្រីតុលាការកម្ពុជានៅតុលាការ' ផងដែរ"[៦៦]។ ម្ចាស់បណ្ដឹងក៏កត់សម្គាល់ផងដែរថា ការលើកឡើងរបស់អ្នកនាំពាក្យរូបនោះ គឺធ្វើឡើងនៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១០ និងចេញផ្សាយក្នុងសារព័ត៌មាននៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០[៦៧]។

៥២. ចៅក្រម យូ ប៊ុនឡេង បានឆ្លើយតបដូចតទៅនេះ៖

> ប្រសិនបើខ្ញុំត្រូវតែស្ដាប់បង្គាប់រាជរដ្ឋាភិបាលមែននោះ ខ្ញុំនឹងមានជំហរមួយច្បាស់លាស់មិនចាំបាច់មានការស្ទាក់ស្ទើរចិត្តនៅក្នុងការបំពេញការងារស៊ើបសួរក្នុងសំណុំរឿងលេខ០០៣ និង

---

[៦៥] បណ្ដឹងជំទាស់ចៅក្រម យូ ប៊ុនឡេង, កថាខណ្ឌ២១(គ) (ជើងទំព័រត្រូវបានលុប)។

[៦៦] បណ្ដឹងជំទាស់ចៅក្រម យូ ប៊ុនឡេង, កថាខណ្ឌ៣ (ជើងទំព័រត្រូវបានលុប)។

[៦៧] បណ្ដឹងជំទាស់ចៅក្រម យូ ប៊ុនឡេង, កថាខណ្ឌ៩ និងជើងទំព័រ២២។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

លេខ០០៤ ឡើយ។ លើសពីនេះទៅទៀត នៅក្នុងដំណើរការពិចារណារបស់ខ្ញុំ ខ្ញុំក៏ធ្លាប់គិតថា អាចជាពេលវេលាសមស្របសម្រាប់ចំណាត់ការរឿងក្តីនេះ ហើយបានចុះហត្ថលេខាលើសេចក្តីព្រាងដីកាចាត់ឱ្យស៊ើបសួរជំនួសដែលលោក Marcel Lemonde បានប្រគល់មកខ្ញុំផងដែរ។ ការស្ទាក់ស្ទើរ និងការធ្លាប់ចុះហត្ថលេខារបស់ខ្ញុំលើសេចក្តីព្រាងដីកានោះបានបង្ហាញរួចទៅហើយថា នេះគឺជាការបង្ហាញឆន្ទៈច្បាស់លាស់ និងពិតប្រាកដរបស់ខ្ញុំចំពោះសំណុំរឿង ០០៣ និង០០៤ នេះ។

ការស្ទាក់ស្ទើរចិត្ត [របស់ខ្ញុំ] មានតាំងពីដើមខែមិថុនាមកម្ល៉េះ...

ការចុះហត្ថលេខា [របស់ខ្ញុំ] នៅលើសេចក្តីព្រាងដីកាចាត់ឱ្យស៊ើបសួរជំនួស ដែលស្ថិតនៅជាសេចក្តីព្រាង និងមិនទាន់មានសុពលភាពនៅឡើយដោយហេតុថាក្រឡាបញ្ជីមិនទាន់ទទួលបានសេចក្តីព្រាងដីកាទាំងនេះពីខ្ញុំនៅឡើយទេ...

ក្រុមមេធាវីការពារក្តីខកខានមិនបានបង្ហាញភស្តុតាង អំពីថាតើខ្ញុំពិតជាបានទទួលបញ្ជាពីអំណាចនីតិប្រតិបត្តិ នៅក្នុងការបំពេញការងារជាសហចៅក្រមស៊ើបអង្កេតរបស់ អ.វ.ត.ក ហើយក៏មិនបានបង្ហាញដែរទេ ថាតើអ្វីដែលជាផលប្រយោជន៍របស់ខ្ញុំនៅក្នុងការស្តាប់តាមបញ្ជារបស់អំណាចនីតិប្រតិបត្តិនោះ។ ការលើកឡើងជាលក្ខណៈទូលំទូលាយបែបនេះមិនអាចយកមកធ្វើជាមូលដ្ឋាននៃបណ្តឹងដិតចិត្តបានឡើយ។

ក្រុមមេធាវីការពារក្តីខកខានមិនបានបញ្ជាក់អំពីសកម្មភាពជាក់លាក់ណាមួយរបស់ខ្ញុំ ក្រៅអំពីចំណាត់ការផ្នែកតុលាការដែលឈរទៅលើគោលការណ៍ច្បាប់ត្រឹមត្រូវ ដើម្បីអាចឱ្យមានព័ត៌មានគ្រប់គ្រាន់សម្រាប់អ្នកសង្កេតការណ៍ឯករាជ្យមួយយល់ឃើញថា ខ្ញុំមានភាពលម្អៀងនៅក្នុងសំណុំរឿងលេខ ០០២ ឡើយ។ ម្យ៉ាងវិញទៀត ក្នុងនាមជាអ្នកច្បាប់ មិនអាចនឹងយកព័ត៌មានដែលគ្មានលក្ខខណ្ឌនៃភស្តុតាងមកអះអាងសើៗបានដែរ[៦៨]។

## ការពិចារណាដោយអង្គបុរេជំនុំជម្រះ

[៦៨] ចម្លើយតប, កថាខណ្ឌ២៥-២៧, ២៩, ៣២។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. * C.E.T.C.

៥៣. អង្គបុរេជំនុំជម្រះមិនឯកភាពជាមួយការអះអាងការពិតរបស់ម្ចាស់បណ្តឹង ដែលថាចៅក្រម យូ ប៊ុនឡេង បានសម្រេចចិត្តលុបហត្ថលេខារបស់គាត់ "ភ្លាមៗបន្ទាប់ពី" អ្នកនាំពាក្យរូបនោះបានលើកឡើងជាសាធារណៈ។ ជាការពិតដែលថាការលើកឡើងរបស់អ្នកនាំពាក្យរូបនោះធ្វើឡើងនៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១០ ហើយក្រោយមកត្រូវបានចេញផ្សាយក្នុងសារព័ត៌មាននៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០[៦៩]។ ក៏ប៉ុន្តែ យើងមិនច្បាស់ថា តើនៅពេលណា រវាងថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១០ (កាលបរិច្ឆេទដែលចៅក្រម យូ ប៊ុនឡេង បានចុះហត្ថលេខាលើសេចក្តីព្រាងដីកាចាត់ឱ្យស៊ើបសួរជំនួស[៧០]) និងថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០ (កាលបរិច្ឆេទនៃអនុស្សរណៈផ្ទៃក្នុងពីសហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង ទៅសហចៅក្រមស៊ើបអង្កេត Marcel Lemonde) ដែលចៅក្រម យូ ប៊ុនឡេង បានសម្រេចចិត្តថាគាត់នឹងលុបហត្ថលេខារបស់គាត់។ ដោយមិនមានការបញ្ជាក់ ម្ចាស់បណ្តឹងគ្រាន់តែសន្និដ្ឋានថា ចៅក្រម យូ ប៊ុនឡេង បានសម្រេចចិត្ត "ភ្លាមៗបន្ទាប់ពី" ការលើកឡើងរបស់អ្នកនាំពាក្យ ឬការចេញផ្សាយព័ត៌មាន។ បើទោះបីជា ចៅក្រម យូ ប៊ុនឡេង បានសម្រេចចិត្តលុបហត្ថលេខារបស់គាត់បន្ទាប់ពីការលើកឡើងរបស់អ្នកនាំពាក្យ ឬការចេញផ្សាយព័ត៌មានក៏ដោយ ក៏ប្រការតែមួយនេះមិនបញ្ជាក់ឱ្យឃើញថា ចៅក្រម យូ ប៊ុនឡេង បានបំពេញកិច្ចដោយគ្មានឯករាជ្យភាព ឬអនាគតិនោះទេ។ អង្គបុរេជំនុំជម្រះក៏សូមរំលឹកម្ចាស់បណ្តឹងថា វាគឺជាឆន្ទានុសិទ្ធិរបស់ចៅក្រម យូ ប៊ុនឡេង ក្នុងការលុបហត្ថលេខារបស់គាត់នៅលើឯកសារមុនពេលដែលវានឹងត្រូវបានជូនដំណឹង។

៥៤. អង្គបុរេជំនុំជម្រះក៏កត់សម្គាល់ផងដែរថា អ្នកដាក់ពាក្យបណ្តឹងមិនបានផ្តល់ការសន្និដ្ឋានចំពោះលទ្ធភាពដែលថា ទង្វើរបស់ចៅក្រម យូ ប៊ុនឡេង បង្ហាញពីឯករាជ្យភាព និងអនាគតិ ព្រមទាំងស្របតាមឯករាជ្យភាព និងអនាគតិរបស់គាត់នោះទេ។ ឧទាហរណ៍ពីរនៃទង្វើបែបនេះ [redacted]

[៦៩] អត្ថបទរបស់ Douglas Gillison, "សាលាក្តីខ្មែរក្រហមចាប់ផ្តើមស៊ើបអង្កេតជនសង្ស័យប្រាំរូបទៀត នៃរបបកម្ពុជាប្រជាធិបតេយ្យ (KRT begins investigation of five new regime suspects", *ឌឹ ភែមប៉ូឆា ដេលី,* ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០, ទំព័រ២៦។

[៧០] អនុស្សរណៈផ្ទៃក្នុងពីសហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង ទៅសហចៅក្រមស៊ើបអង្កេត Marcel Lemonde។

[redacted] និង សេចក្តីសម្រេចដំបូងរបស់គាត់ក្នុងការចុះហត្ថលេខាលើសេចក្តីព្រាងដីកាចាត់ឱ្យស៊ើបសួរជំនួស។

៥៥. ដូច្នេះ អង្គបុរេជំនុំជម្រះបដិសេធសេចក្តីសន្និដ្ឋានរបស់ម្ចាស់បណ្តឹងទាក់ទងនឹងទង្វើទីបីរបស់ចៅក្រម យូ ប៊ុនឡេង រួមទាំងសេចក្តីសន្និដ្ឋានដទៃទៀតនៅក្នុងពាក្យបណ្តឹង និងសេចក្តីបន្ថែម ដោយហេតុថាសេចក្តីសន្និដ្ឋានទាំងនេះ មិនបញ្ជាក់ថា ចៅក្រម យូ ប៊ុនឡេង បានបំពេញកិច្ច ឬទំនងជាបានបំពេញកិច្ចដោយគ្មានឯករាជ្យភាព ឬអនាគតិឡើយ។

**ដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទ៖**

១. **យល់ឃើញថា** ពាក្យបណ្តឹង សេចក្តីបន្ថែម ចម្លើយតប និងការសង្កេតទៅលើសេចក្តីបន្ថែម អាចទទួលយកបាន និង

២. **បដិសេធចោល** អង្គសេចក្តីនៃពាក្យបណ្តឹង និងសេចក្តីបន្ថែម។

ដោយអនុលោមតាមវិធាន ៣៤(៨) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

ភ្នំពេញ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០

**អង្គបុរេជំនុំជម្រះ**

Rowan DOWNING **ន៉ី ធុល** Catherine MARCHI-UHEL **ហ៊ួត វុទ្ធី** **ប្រាក់ គីមសាន**